ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

លេខ : ០៧/ ២៧១/៣៣៣០

ថ្ងៃ................ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០២០

នាយកដ្ឋានបណ្ដុះបណ្ដាល
ចូល លេខ 201 ម៉ោង 9-30
ថ្ងៃទី 7 ខែ 7 ឆ្នាំ 20
បញ្ជូន..................

# របាយការណ៍
# ស្ដីពី
# សកម្មភាព និងលទ្ធផលការងារប្រចាំខែមិថុនា និងទិសដៅបន្ត សម្រាប់ខែកក្កដា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានរដ្ឋបាល

28/07/2020

អគ្គនាយកដ្ឋានរដ្ឋបាល គឺជាអង្គភាពមួយក្នុងចំណោមអង្គភាពទាំង១១ ចំណុះក្រសួងមហាផ្ទៃ មានតួនាទីជាសេនាធិការឱ្យក្រសួង ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា ព្រមទាំងសម្របសម្រួលក្នុងការបង្កើត ការចុះបញ្ជី និងគ្រប់គ្រងសកម្មភាពសមាគម អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ។

ក្នុងខែមិថុនា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តការងារតាមតួនាទី ភារកិច្ច ដោយសម្រេចលទ្ធផលបានដូចខាងក្រោម៖

## I-សកម្មភាពការងារ និងលទ្ធផល

### ១-ការងារលិខិតស្នាម និងឯកសារផ្សេងៗ

-បានទទួលលិខិត និងឯកសារ ដែលបញ្ជូនមកពីអគ្គលេខាធិការដ្ឋាន និងអង្គភាពនានាចំណុះ ក្រសួងមហាផ្ទៃ សរុបចំនួន ៩៨៣ច្បាប់ និងបានធ្វើការបែងចែកជូនទៅនាយកដ្ឋានចំណុះរួមមាន៖នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ៦៣០ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៣៩ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ១៦៦ច្បាប់ នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន២០ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ៣៥ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន៩៣ច្បាប់។

-បានទទួលលិខិតមកពីនាយកដ្ឋានជំនាញចំណុះអគ្គនាយកដ្ឋានរដ្ឋបាលចំនួន ៣០២ច្បាប់ ដែលក្នុងនោះមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ៨៥ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ២៥ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ១០៣ច្បាប់ នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន ១៥ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ១៩ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៥៥ច្បាប់ ដើម្បីដាក់ជូនអគ្គនាយកជ្រាបជារបាយការណ៍ និងពិនិត្យសម្រេច។

-បានចាត់ចែងបញ្ជូនឯកសារចំនួន ២២២ច្បាប់ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងជ្រាបជារបាយការណ៍និងពិនិត្យសម្រេច ដែលក្នុងនោះឯកសារមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ៦០ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ១៥ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ៨៦ច្បាប់ នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន ០៥ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ១០ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៤៦ច្បាប់។

-បានទទួលឯកសារចំនួន ១៤៦ច្បាប់ ដែលថ្នាក់ដឹកនាំក្រសួងមហាផ្ទៃពិនិត្យ សម្រេចរួច និងបញ្ជូនទៅនាយកដ្ឋានចំណុះ ដើម្បីចាត់ចែងបន្តរួមមានៈ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ៣២ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន១២ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ៦២ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ០៤ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ០៨ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ២៨ច្បាប់។

**២-ការងារចេញលិខិតបង្គាប់ការ និង លិខិតបញ្ជាបេសកកម្ម**

ក្នុងខែមិថុនា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានចេញលិខិតបង្គាប់ការ និងលិខិតបញ្ជាបេសកកម្មសរុបចំនួន ១២៤ច្បាប់(ក្នុងនោះលិខិតបង្គាប់ការ ៥៥ច្បាប់ និងលិខិតបញ្ជាបេសកកម្ម ៦៩ច្បាប់) ជូនថ្នាក់ដឹកនាំ និង មន្ត្រីចំណុះអគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីចុះទៅបំពេញបេសកកម្មនៅតាមបណ្តាខេត្តនានា ។ ជាមួយគ្នានេះដែរអគ្គនាយកដ្ឋានរដ្ឋបាល ក៏បានចុះទិដ្ឋាការជូនមន្ត្រីរាជការមកពីបណ្តាខេត្ត ដែលមកបំពេញបេសកកម្មនៅក្រសួងមហាផ្ទៃផងដែរ។

**៣-ការងារប្រជុំ និងសិក្ខាសាលាផ្សេងៗ**

ក្នុងខែមិថុនា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាល បានរៀបចំកិច្ចប្រជុំ និងចាត់មន្ត្រីចូលរួមកិច្ចប្រជុំ និងកម្មវិធីនានាដូចខាងក្រោមៈ

-ចូលរួមជាមួយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ក្នុងឱកាសអនុញ្ញាតឱ្យឯកឧត្តម MIKAMI Masahiro ឯកអគ្គរាជទូតជប៉ុនចូលជួបពិភាក្សាការងារពាក់ព័ន្ធនឹងដំណោះស្រាយទៅនឹងបញ្ហាបង្កឡើងដោយជំងឺកូវីដ-១៩។

▪ ការប្រជុំ សិក្ខាសាលាៈ

-ដឹកនាំកិច្ចប្រជុំស្តាប់របាយការណ៍លទ្ធផលសវនកម្មខាងក្រៅ របស់គម្រោងលាក (LEAP) សម្រាប់ឆ្នាំ២០១៩

-ចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការផ្ទេរធនធានថវិកាទៅឱ្យរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ

-ចូលរួមក្នុងកិច្ចប្រជុំឆ្លងផែនការសកម្មភាពឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានកស្តុការ និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន អគ្គលេខាធិការដ្ឋាន និងអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ

-ចូលរួមក្នុងកិច្ចប្រជុំផ្ទៃក្នុងឆ្លងសេចក្តីព្រាងច្បាប់វិសោធនកម្មច្បាប់ស្តីពីអន្តោប្រវេសន៍

-ចូលរួមក្នុងកិច្ចប្រជុំលើកទី១៨ របស់គ.ជ.អ.ប

-ចូលរួមកិច្ចប្រជុំស្តាប់បទបង្ហាញរបស់ក្រុមហ៊ុនទូរគមនាគមន៍ Seatel នៅទីស្តីការក្រសួងមហាផ្ទៃ

- ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលត្រួតពិនិត្យការអនុវត្តគម្រោង LEAP របស់ខេត្តសៀមរាប

-ចូលរួមក្នុងកិច្ចប្រជុំជាមួយអង្គការតម្លាភាពកម្ពុជា ស្តីពីការបង្កើត Mobile Application សម្រាប់ការរាយការណ៍ព័ត៌មាន ត្រឡប់របស់ពលរដ្ឋលើការផ្តល់សេវាសាធារណៈ

-ចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន និង សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចប្រេងកាត នៅទីស្តីការគណៈរដ្ឋមន្ត្រី និងសញ្ញាសក្តិរបស់មន្ត្រីរាជការអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់កិច្ចការប្រកួតប្រជែង និង បង្ក្រាបការក្លែងបន្លំនៃក្រសួងពាណិជ្ជកម្ម

-ចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិភាក្សាលើការងារគ្រប់គ្រងដែនជម្រកសត្វព្រៃ " ព្រៃឡង់ " ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង នៅទីស្តីការក្រសួងបរិស្ថាន

-ចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ លើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ (ក.វ.ក) ៣ឆ្នាំរំកិល ២០២១-២០២៣ ដែលរៀបចំដោយក្រសួងផែនការ

-ចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេសដើម្បីពិភាក្សា លើសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក)២០១៦-២០៣០ ដែលរៀបចំដោយក្រសួងផែនការ

-ចូលរួមក្នុងកិច្ចប្រជុំបច្ចេកទេសស្តីពីសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិរក្ស និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច នៅកម្ពុជា

-ចូលរួមក្នុងកិច្ចប្រជុំស្តីពីការពិនិត្យ និងដោះស្រាយផលប៉ះពាល់ពីការបញ្ឈប់សិទ្ធិធ្វើអាជីវកម្មភាស៊ីផ្សារចាស់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង មុនចប់អាណត្តិកិច្ចសន្យារបស់អ្នកវិនិយោគលោក សា លាង នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីការកសាងស្ពានថ្មីនៅច្រកទ្វារព្រំដែនអន្តរជាតិព្រំ(ប៉ៃលិន)បានផាកកាដ(ចន្ទបុរី)

-ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាអំពីគម្រោងកម្មវិធីដើម្បីការពារពលករទេសន្តប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ និងសហគមន៍ ពីហានិភ័យនៃការឆ្លងជំងឺកូវីដ១៩ទ្រង់ទ្រាយធំ និងការផ្តល់សេវាសេដ្ឋកិច្ចសង្គមសំខាន់ៗ

-ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមការងារនៃអង្គការJICA អំពីក្របខណ្ឌកិច្ចសហប្រតិបត្តិការរវាងក្រសួងមហាផ្ទៃកម្ពុជា ជាមួយនឹងអង្គការ JICA ចាប់ពីឆ្នាំ២០២២តទៅ

-ចូលរួមក្នុងកិច្ចប្រជុំពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងចុងក្រោយស្តីពីផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តភាពឆ្នាំ២០១៩-២០២៣ សម្រាប់ក្រុងគោលដៅ នៅទីស្តីការក្រសួងបរិស្ថាន

-ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពីការរៀបចំឯកសារពាក់ព័ន្ធការងារអប់រំជាមួយតំណាងមកពីក្រសួងអប់រំយុវជន និងកីឡា នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមក្នុងកិច្ចប្រជុំ ស្តីពីការរៀបចំចុះត្រួតពិនិត្យ និងវាយតម្លៃលើនីតិវិធី នៃការអនុវត្តគម្រោងលើកកម្ពស់ជីវភាពប្រជាជនក្រីក្រ (LEAP)នៅរាជធានីភ្នំពេញ

-ចូលរួមក្នុងកិច្ចប្រជុំពិនិត្យ លើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផល នៃការអង្កេតស្រាវជ្រាវករណីបណ្តឹងរបស់លោក **ឡៅ វិសេស** និងភរិយាឈ្មោះ **វង្ស កែវលីនណា** តំណាងប្រជាពលរដ្ឋចំនួន ០៧គ្រួសារ ប្តឹងលោក **លុយ ស៊ីលីញ** និង លោកស្រី **យីន សុខន** ថាបានរំលោភយកដីរបស់ពួកគាត់ទំហំ ៣០២.៤៣៩,៦៤ ម៉ែត្រការ៉េ ស្ថិតនៅចំណុចវាលស្មៅចិញ្ចៀន ភូមិលើ ឃុំស្វាយជ្រុំ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល នៅទីស្តីការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

-ចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងដោះស្រាយលើករណី៖ ១.សំណើសុំធ្វើអនុបយោគ និងផ្ទេរការចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តកែប ទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងយុត្តិធម៌សម្រាប់សាងសង់អគារសាលាដំបូងខេត្តកែប ២.សំណើសុំកាត់ដីទំហំ ១១.៩២៥ម៉ែត្រការ៉េ (ដីអតីតកាស៊ីណូ) ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តកែបដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ៣.សំណើសុំកាត់ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នូវដីទំហំ ៣០៦ម៉ែត្រការ៉េ និងអគារលើដីទំហំ ២២៥ម៉ែត្រការ៉េ ដើម្បីប្រទានកម្មជូនប្រជាពលរដ្ឋ ៤.សំណើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល លើផ្ទៃដីរួមទំហំ ៨.៤១៤ម៉ែត្រការ៉េ ដើម្បីប្រទានកម្មជូនប្រជាពលរដ្ឋ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

▪ **កម្មវិធីផ្សេងៗ៖**

-ចូលរួមពិធីប្រកាសចូលកាន់មុខតំណែងរបស់អភិបាល និងអភិបាលរង នៃគណៈអភិបាលខេត្តកែប

-ចូលរួមជាអធិបតី ក្នុងពិធីប្រកាសតែងតាំងមុខតំណែងមន្ត្រីរាជការ ក្នុងរចនាសម្ព័ន្ធនាយកដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

-ចូលរួមក្នុងពិធីផ្សព្វផ្សាយ និងដាក់ឱ្យដំណើរការជាផ្លូវការមន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានី ខេត្ត

-ចូលរួមស្តាប់បទបង្ហាញរបស់ក្រុមហ៊ុន KESS អំពីការតភ្ជាប់ប្រព័ន្ធសេវាទូទាត់វិក័យបត្រនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។

**៤-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត**

**៤.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុង**

**៤.១.១-លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន** (គ្មាន)

### ៤.១.២-លិខិតបទដ្ឋានគតិយុត្តដែលកំពុងរៀបចំ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបចោលភូមិ និងការកែសម្រួលព្រំប្រទល់រដ្ឋបាល ថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី នីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីណែនាំ ស្តីពីការវាយតម្លៃជ្រើសរើសរដ្ឋបាល ក្រុង ស្រុក ខណ្ឌឆ្នើម ក្នុងការផ្តល់សេវារដ្ឋបាល

-សេចក្តីព្រាងសេចក្តីណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការដាក់ឱ្យប្រើប្រាស់ទម្រង់ដីកានានាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីជូនដំណឹងស្តីពីការគ្រប់គ្រងមន្ត្រីរាជការនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌបន្ទាប់ពីការធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មី

-សេចក្តីព្រាងគំរូកិច្ចសន្យា ស្តីពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលក្រុង ស្រុក

-សេចក្តីព្រាងសៀវភៅណែនាំស្តីពីកម្មវិធីពានរង្វាន់សម្រាប់ការអនុវត្តសេវាសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសៀវភៅណែនាំស្តីពី"កិច្ចការរដ្ឋបាល"សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា(ផ្នែករដ្ឋបាលស៊ីវិល)ចំណុះទីស្តីការក្រសួងមហាផ្ទៃ។

### ៤.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

### ៤.២.១-លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន (គ្មាន)

### ៤.២.២-លិខិតបទដ្ឋានគតិយុត្តកំពុងសហការរៀបចំ

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យថ្មី ស្តីពីការគ្រប់គ្រងច្រកទ្វារព្រំដែននៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-សេចក្តីព្រាងកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤៣ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិកាឧបត្ថម្ភលើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួង ស្តីពីនីតិវិធី នៃការចុះបញ្ជីសិប្បកម្មដែលមានដើមទុនសមមូលលើសពី៨០លានរៀលដល់២០០លានរៀល និងគ្មានហានិភ័យ

-សេចក្តីព្រាង សេចក្តីណែនាំអន្តរក្រសួង ស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០២០-២០៣០។

**៥-ការងារបុគ្គលិក**

**៥.១-ការងារក្របខ័ណ្ឌ**

គិតត្រឹមខែមិថុនា ឆ្នាំ២០២០ ស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃសរុបមានចំនួន **៧.០៦៩រូប/ស្រី១.២៤៧រូប** (ក្នុងនោះក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន **៩៩០រូប/ស្រី ២៤៥រូប** ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិចំនួន **២.៩៦០រូប/ស្រី ៥៣៨រូប** ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ជាតិចំនួន **១.១៧៤រូប/ស្រី ១៨៨រូប** ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ក្រោមជាតិចំនួន **១.៩៤៥រូប/ស្រី ២៧៦រូប**) បើប្រៀបធៀបទៅនឹង ខែឧសភា ឆ្នាំ២០២០ ក្របខ័ណ្ឌថយចុះចំនួន **០៦រូប/ស្រី០៤រូប** ។ ជាមួយគ្នានេះដែរ ក្រសួងមហាផ្ទៃក៏បានបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលពីក្របខ័ណ្ឌក្រសួងនានាចំនួន **០៤រូប/ស្រី០០រូប** ក្របខ័ណ្ឌចេញចំនួន **១០រូប/ស្រី០៤រូប**(ក្នុងនោះផ្ទេរទៅក្នុងក្របខ័ណ្ឌក្រសួងនានាចំនួន **០៨រូប/ស្រី០២រូប** លុបឈ្មោះដោយមរណភាពចំនួន **០១រូប/ស្រី០១រូប** និងលុបឈ្មោះដោយស្ថិតក្នុងភាពទំនេរគ្មានបៀវត្សហួសការកំណត់ចំនួន **០១រូប/ស្រី០១រូប**)។

**៥.២-ការងារគោលនយោបាយមន្ត្រីរាជការ**

ក្នុងខែមិថុនា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានអនុញ្ញាតឱ្យមន្ត្រីរាជការ និងមន្ត្រីពន្ធនាគារឈប់សម្រាកពីការងារដោយ លំហែមាតុភាពចំនួន**០៧រូប** ក្នុងនោះមន្ត្រីរាជការស៊ីវិលចំនួន **០៣រូប** និងពន្ធនាគារចំនួន **០៤រូប** ទន្ទឹមនោះក៏បានផ្តល់ប័ណ្ណសំគាល់ខ្លួនជូនប្រធានក្រុមប្រឹក្សាខេត្ត សមាជិកក្រុមប្រឹក្សាខេត្ត មន្ត្រីរាជការក្រសួងមហាផ្ទៃសរុបចំនួន **៧១រូប/ស្រី១០រូប** (ក្នុងនោះសមាជិកក្រុមប្រឹក្សាខេត្តចំនួន **៤២រូប/ស្រី០៥រូប** និងមន្ត្រីរដ្ឋបាលជាន់ខ្ពស់ចំនួន **២៩រូប/ស្រី០៥រូប**)។ជាមួយគ្នានេះផងដែរ ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃបានផ្តល់គ្រឿងឥស្សរិយយសថ្នាក់ជាតូបការ ជាកិច្ចមច្ចាមរណៈជូនសព **ឯកឧត្តម ម៉ី មគ្គ** ទីប្រឹក្សាក្រសួងមហាផ្ទៃ។

**៥.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ**

ក្នុងខែមិថុនា ឆ្នាំ២០២០ ស្ថានភាពបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិលតាមមុខតំណែង ដែលកំពុងបម្រើការងារនៅគ្រប់អគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួងមហាផ្ទៃសរុបចំនួន **៩៩០រូប/ស្រី២៤៥រូប ស្មើនឹង២៤.៧៤%** ដែលក្នុងនោះរួមមាន៖

-មន្ត្រីរាជការស៊ីវិលចំនួន **៩៧១រូប/ស្រី ២៤៣រូប ស្មើនឹង ២៥,០២%** ក្នុងនោះរួមមាន (រដ្ឋលេខាធិការចំនួន **០៣រូប** អនុរដ្ឋលេខាធិការចំនួន **០៣រូប/ស្រី ០១រូប** អគ្គនាយកចំនួន **០១រូប** អគ្គនាយករងចំនួន **២៨រូប/ស្រី ០២រូប** អគ្គលេខាធិការរងចំនួន **០៤រូប/ស្រី ០១រូប** គណៈកម្មាធិការ គ.ជ.ប.ទចំនួន **០៣រូប** (ក្នុងនោះសមាជិកគណៈកម្មាធិការចំនួន **០១រូប** ប្រធានលេខាធិការដ្ឋានចំនួន **០១រូប** អនុប្រធានលេខាធិការដ្ឋានចំនួន **០១រូប** ) ក្រុមប្រឹក្សានីតិកម្មចំនួន **០៧រូប/ ស្រី០២រូប** (ក្នុងនោះប្រធាន **០១រូប** អនុប្រធាន **០៣រូប/ស្រី០១រូប** សមាជិក **០៣រូប/ស្រី០១រូប**) លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោម-

ជាតិ(គ.ជ.អ.ប)ចំនួន ១៧រូប/ស្រី០៦រូប អគ្គាធិការចំនួន ០១រូប អគ្គាធិការរងចំនួន ០៩រូប/ស្រី០១រូប ប្រធាន-នាយកដ្ឋានចំនួន ១២រូប/ស្រី០១រូប អនុប្រធាននាយកដ្ឋានចំនួន ១៧១រូប/ស្រី២៩រូប ប្រធានការិយាល័យចំនួន ៨៥រូប/ស្រី១៥រូប អនុប្រធានការិយាល័យចំនួន ២៥៨រូប/ស្រី ៧២រូប និងមន្ត្រីចំនួន ៣៧៣រូប/ស្រី១១៤រូប។

-មន្ត្រីដែលផ្ទេរភារកិច្ចពីថ្នាក់ក្រោមជាតិមកទីស្តីការក្រសួងចំនួន ១៩រូប/ស្រី០២រូប ស្មើនឹង១០,៥២%

-មន្ត្រីរាជការក្របខ័ណ្ឌដែលមានមុខតំណែងជាទីប្រឹក្សា និងជំនួយការចំនួន ៥៥៣រូប/ស្រី៥៦រូប ស្មើនឹង ១០,១២% ។ ក្នុងខែមិថុនា ឆ្នាំ២០២០នេះដែរ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ បានពិនិត្យ សម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ច ផ្លាស់ប្តូរកន្លែងធ្វើការជូនមន្ត្រីរាជការស៊ីវិលនៅថ្នាក់ជាតិសរុបចំនួន៨៦រូប/ស្រី២២រូប។

**៥.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

គិតត្រឹមខែមិថុនា ឆ្នាំ២០២០ ស្ថានភាពបច្ចុប្បន្នភាពនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសសរុបចំនួន ៩,២២៧រូប/ស្រី២,៦៦៦រូប ដូចខាងក្រោម ៖

-គណៈអភិបាលរាជធានី ខេត្តសរុបចំនួន១៧៥រូប/ស្រី២៧រូប ស្មើនឹង១៥,៤២% ក្នុងនោះ(អភិបាលរាជធានី ខេត្តចំនួន ២៥រូប/ស្រី០១រូប អភិបាលរងរាជធានី ខេត្តចំនួន ១៥០រូប/ស្រី២៦រូប)គណៈអភិបាលក្រុង ស្រុក ខណ្ឌសរុបចំនួន៩៣៨រូប/ស្រី១៩៨រូប ស្មើនឹង២១.១១% ក្នុងនោះ(អភិបាលក្រុង ស្រុក ខណ្ឌចំនួន ២០៣រូប/ស្រី០៧រូប អភិបាលរងក្រុង ស្រុក ខណ្ឌចំនួន ៧៣៥រូប/ស្រី ១៩១រូប)

-មន្ត្រីស្ថិតក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសរុបចំនួន ៦.៤៦៨រូប/ស្រី២.១៤៣រូប ស្មើនឹង ៣៣.១៣% ក្នុងនោះ (សាលារាជធានី ខេត្តចំនួន ២.៨០៧រូប/ស្រី៩១០រូប ស្មើនឹង ៣២.៤២% សាលាក្រុង ស្រុក ខណ្ឌសរុបចំនួន ៣.៦៦១រូប/ស្រី១.២៣៣រូប ស្មើនឹង ៣៣,៦៨%) ស្មៀនឃុំ សង្កាត់ចំនួន ១.៦៤៦រូប/ស្រី ២៩៨រូប ស្មើនឹង ១៨.១% និងប្រធានទីស្នាក់ការច្រកទ្វារព្រំដែនចំនួន ៥៤រូប ។ ទន្ទឹមនេះដែរ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃក៏បានពិនិត្យសម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ច ជូនអភិបាល អភិបាលរងនៃគណៈអភិបាល រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលសាលាខេត្ត ក្រុង ស្រុក ខណ្ឌ និងផ្លាស់ប្តូរភារកិច្ច និងតែងតាំងស្មៀន ឃុំ សង្កាត់សរុបចំនួន ៣៧រូប/ស្រី០២រូប (ដូចក្នុងឧបសម្ព័ន្ធ១ក-១ឃ)។

**៥.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

ស្ថានភាព បច្ចុប្បន្នភាពសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ទូទាំងប្រទេសមានដូចខាងក្រោម៖

-សមាសភាពក្រុមប្រឹក្សារាជធានី ខេត្តសរុបចំនួន ៥៣៤រូប/ស្រី៩៣រូប (ស្មើនឹង ១៦,៦៣%) ក្នុងនោះ (ប្រធានក្រុមប្រឹក្សារាជធានី ខេត្តចំនួន ២៥រូប សមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន ៥៣៤រូប/ស្រី ៩៤រូប)។

-សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌសរុបចំនួន ៣.៥៥៥រូប/ស្រី៦២៣រូប(ស្មើនឹង១៧,៥២%)ក្នុងនោះ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ២០៣រូប/ស្រី០៥រូប សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ៣.៣៥២រូប/ស្រី៦១៨រូប។

-សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់សរុបចំនួន ១១.៥៧២រូប/ស្រី២.៣៨២រូប(ស្មើនឹង២០.៥៧%)(ក្នុងនោះ មេឃុំចំនួន ១.៤០៥រូប/ស្រី ១១០រូប ចៅសង្កាត់ចំនួន ២៤១រូប/ស្រី ២៦រូប ជំទប់ទី១ ចំនួន ១.៤០៥រូប/ស្រី ២២៥រូប ជំទប់ទី២ចំនួន ១.៤០៥ រូប/ស្រី៣០៧រូប ចៅសង្កាត់រងទី១ ចំនួន ២៤១រូប/ស្រី ៦២រូប ចៅសង្កាត់រងទី២ ចំនួន ២៤១រូប/ស្រី៥២រូប និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ៦.៦៣៤រូប/ស្រី១.៥៦០រូប)។ ក្នុងខែមិថុនា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានផ្លាស់ប្តូរ និងទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ចំនួន ០២រូប/ស្រី០១រូប(ដូចក្នុងឧបសម្ព័ន្ធ២ក)សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន១១រូប/ស្រី០៣រូប (ដូចក្នុងឧបសម្ព័ន្ធ២ខ) និងសមាសភាពសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ចំនួន ១១រូប (ដូចក្នុងឧបសម្ព័ន្ធ២គ)។

**៥.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

ស្ថានភាពប្រវត្តិរូបមន្ត្រីរាជការស៊ីវិលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យសរុបចំនួន ៩.៨៨៣រូប/ស្រី ២.៧៨២រូប(ក្នុងនោះមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន ៨៨៩រូប/ស្រី ២០១រូប និងមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិចំនួន ៨.៩៩៤រូប/ស្រី២.៥៨១រូប)។

### ៦-ការងារអភិវឌ្ឍន៍សមត្ថភាព

#### ៦.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស

ក្នុងខែមិថុនា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានរៀបចំ និងចាត់បញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលដូចខាងក្រោម៖

-បានចាត់បញ្ជូនមន្ត្រីចំនួន ០៥រូប/ស្រី០២រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលជំនាន់ទី២ឆ្នាំ២០២០នៅសាលប្រជុំជាន់ទី៣ នៃនាយកដ្ឋានសុចរិតភាព និងអភិបាលកិច្ច ក្រសួងមហាផ្ទៃ

-បានរៀបចំបញ្ចប់វគ្គបណ្តុះបណ្តាលតម្រង់ទិសស្តីពីការគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់ក្រុមគោលដៅនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅខេត្តកំពង់ធំ ត្បូងឃ្មុំ ស្វាយរៀង ស្ទឹងត្រែង តាកែវ បន្ទាយមានជ័យ និងរាជធានីភ្នំពេញ។

-បានចុះសម្ភាសស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីប្រមូលព័ត៌មានរៀបចំវគ្គបណ្តុះបណ្តាលស្មៀន។

#### ៦.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន (គ្មាន)

#### ៦.៣-ការងារព័ត៌មាន និងផ្សព្វផ្សាយ

ចំពោះការងារព័ត៌មាន និងផ្សព្វផ្សាយ អគ្គនាយកដ្ឋានរដ្ឋបាល បាននិងកំពុងរៀបចំសេចក្តីព្រាងព្រឹត្តិបត្រត្រីមាសិក និងវិសេសមាសិកការលេខ ០៤ និងបន្តធ្វើបច្ចុប្បន្នភាពគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ដោយបានបញ្ចូលអត្ថបទចំនួន ៣១ករណី និងបានផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការជ្រើសរើសប្រធានផ្នែកហិរញ្ញវត្ថុ (Chief Finance Office Position) ដើម្បីទៅបម្រើការងារនៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRCS) នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ។

### ៧-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ

#### ៧.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍

ក្នុងកិច្ចគាំទ្របច្ចេកទេស និងអន្តរាគមន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាល បានរៀបចំលិខិតក្នុងនាមក្រសួងមហាផ្ទៃជម្រាបជូនទៅរដ្ឋបាលរាជធានី ខេត្ត និងរៀបចំលិខិតជម្រាបជូនទៅក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាដូចខាងក្រោម៖

-រដ្ឋបាលរាជធានីភ្នំពេញ ករណីឈ្មោះ ហៀង ស្រីនាង ស្នើសុំប្តឹងជំទាស់ចំពោះសាលារៀនទូនហ្វាដែលបានសាងសង់ខ្លោងទ្វារនៅលើផ្លូវសាធារណៈ ស្ថិតក្នុងសង្កាត់អូរឡាំពិក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

-រដ្ឋបាលខេត្តកណ្តាល ករណី៖

• ឈ្មោះ ភួន ភូម៉ូនីរតន៍ ដែលបានស្នើសុំជួយអន្តរាគមន៍លើករណីដីទំហំ ២០ម x៣០ម ចំនួន០៣ឡូតិ៍ប្លុកG១៦ (ឡូតិ៍លេខ ១៨ លេខ២០ និងលេខ២១) លើទីតាំងក្បាលដីលេខ ០៨០១០៥០៥-០៦៨០ ដែលគាត់បានទិញពីក្រុមហ៊ុន លាន ហេង ត្រេឌីង (បូរីកាំងម៉េង) ស្ថិតនៅក្នុងភូមិព្រែកកំពឹស ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

• តំណាងប្រជាពលរដ្ឋ ៣១គ្រួសារ ស្នើសុំប្តឹងឈ្មោះ យ៉ែម សារឿន ពីបទក្លែងបន្លំឯកសារ ដោយបន្លំខ្លួនធ្វើជាតំណាងប្រជាពលរដ្ឋសហគមន៍បឹងកញ្ច្រាំចំនួន ៣១គ្រួសារ ដើម្បីទាមទារដីទំហំ ៨,៦ហិកតា ស្ថិតនៅភូមិព្រែកក្តី ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្តាល មកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។

-រដ្ឋបាលខេត្តតាកែវ ករណីគណនីឈ្មោះ Sophea Lion ផ្ញើសារចូលក្នុងគេហទំព័រហ្វេសប៊ុករបស់សម្តេចក្រឡាហោម ពាក់ព័ន្ធនឹងករណីស្មៀនឃុំព្រៃរំដេង ស្រុកគិរីវង់ ខេត្តតាកែវ មិនធ្វើសំបុត្រកំណើតកូនឱ្យពួកគាត់។

-រដ្ឋបាលខេត្តត្បូងឃ្មុំ៖

• ករណីស្នើសុំគោលការណ៍អនុញ្ញាតដោះដូរដីជូនប្រជាពលរដ្ឋចំនួន ០២គ្រួសារដែលរងផលប៉ះពាល់ដីធ្លីនៅតំបន់រដ្ឋបាលប្រមូលផ្តុំទីរួមខេត្តត្បូងឃ្មុំ។

• ករណីប្រើប្រាស់កម្លាំងរបស់គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ធ្វើអន្តរាគមន៍តាមផ្លូវច្បាប់ ដើម្បីឱ្យក្រុមហ៊ុនហាមុីនី វៃ អ៊ិនវេសមិន បានឈូសឆាយលើដីដែលជាកម្មសិទ្ធិស្របច្បាប់របស់ក្រុមហ៊ុនស្ថិតនៅឃុំត្រពាំងព្រីង ស្រុកតំបែរ ខេត្តត្បូងឃ្មុំ។

-រដ្ឋបាលខេត្តកែប ករណីរៀបចំប្រកាសស្តីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តកែប។

-រដ្ឋបាលខេត្តស្វាយរៀង ករណីឈ្មោះ ញឹម ផលឡៃ ស្នើសុំអន្តរាគមន៍លើចំណាត់ការដោះស្រាយផលប៉ះពាល់នៃការកសាងលូរំដោះទឹកក្នុងគម្រោងសាងសង់របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានទីតាំងស្ថិតនៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង។

-រដ្ឋបាលខេត្តកំពង់ធំ ករណីតំណាងប្រជាពលរដ្ឋចំនួន ៣៣០នាក់ ស្នើសុំអន្តរាគមន៍ ធ្វើការអង្កេតស្រាវជ្រាវករណីមន្ត្រីរដ្ឋបាលព្រៃឈើរំលោភបំពានដីធ្លីរបស់ពួកគាត់ ស្ថិតនៅភូមិអូរគគីរ ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ

-រដ្ឋបាលខេត្តកំពង់ស្ពឺ ករណីៈ

- គណនីឈ្មោះ PoPo ផ្ញើសារចូលក្នុងគេហទំព័រហ្វេសប៊ុករបស់ សម្តេចក្រឡាហោម ពាក់ព័ន្ធនឹង ករណីឈ្មោះ ជា យូធិន ជាមន្ត្រីរាជការក្រសួងមហាផ្ទៃ បានបញ្ជាឱ្យកូនចៅចាប់ប្តីរបស់គាត់ឈ្មោះ សឿន រុនកាលពីថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២០ ដោយចោទពីបទមនុស្សឃាត និងបានរុះរើផ្ទះរបស់ពួកគាត់ដែលបានរស់នៅតាំងពីឆ្នាំ២០០៦ ស្ថិតនៅលើខ្នងភ្នំគិរីរម្យ ភូមិថ្មី ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

- អង្គភាពប្រឆាំងអំពើពុករលួយ ករណីអង្គការទប់ស្កាត់ការបំផ្លាញធនធានធម្មជាតិ និងការការពារសិទ្ធិពលរដ្ឋស្នើសុំអន្តរាគមន៍ ដើម្បីឱ្យឈ្មោះម៉ិញ ឈុំ ដែលមានក្បាលដីលេខ ៥៨៨ និងឈ្មោះម៉ិញ ឈឹម មានក្បាលដីលេខ ៥៨៩ ដែលមានទីតាំងដីស្ថិតនៅភូមិតាម៉ុល សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ បានធ្វើប័ណ្ណកម្មសិទ្ធិ និងអាស្រ័យផលស្របច្បាប់។

-រដ្ឋបាលខេត្តព្រះសីហនុ ករណីៈ

- គណនីឈ្មោះ **Ma Ly** ផ្ញើសារចូលក្នុងគេហទំព័រហ្វេសប៊ុករបស់ សម្តេចក្រឡាហោម ស្នើសុំអន្តរាគមន៍ជួយដោះស្រាយវិវាទដីធ្លីទំហំ ០៧ហិកតា ស្ថិតនៅភូមិអូរត្រជាក់ចិត្ត ឃុំសំរ៉ុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

- ឈ្មោះ **វេង សេង** ស្នើសុំអន្តរាគមន៍ ដើម្បីជួយពន្លឿនឱ្យក្រុមហ៊ុន Attwood Investment Group ដោះស្រាយបញ្ហាបើកផ្លូវទឹក ផ្លូវគោក ដែលគាត់ធ្លាប់បានចេញចូលអាស្រ័យផល និងកាន់កាប់ដីកម្មសិទ្ធិស្របច្បាប់។

- ប្រជាពលរដ្ឋចំនួន ៥៨គ្រួសារ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុ ចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង និងកំណត់ព្រំដីទំហំ ២០៧ហិកតា ដើម្បីចុះបញ្ជីក្បាលដី និងចេញប័ណ្ណកម្មសិទ្ធិ ស្ថិតនៅភូមិឬទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

- ឈ្មោះសេង ចាយ ស្នើសុំអន្តរាគមន៍ជួយបង្កើតគណៈកម្មការចម្រុះថ្នាក់ខេត្ត និងចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំ អង្កេត និងសុំកាត់ឆ្វៀលដីទំហំ ០៩ហិកតា ៧៥អា ចេញពីតំបន់គម្របព្រៃឈើ ដើម្បីចុះបញ្ជីក្បាលដី កសាងប័ណ្ណកម្មសិទ្ធិ និងផ្លាស់ប្តូរប័ណ្ណកម្មសិទ្ធិថ្មី ស្ថិតនៅភូមិស្រែចាមលើ ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

- ឈ្មោះ **ពេជ្រ សូរិយា, ហ៊ីង សុវណ្ណ, ផេង ប៊ុនធឿន, សំ ប៉ាក់, សៀង ផាត, មាស រតនា, ខឹម សុផល, អ៊ឹម ម៉ៅ, ជីវ ជីន** និងឈ្មោះ **ជូ សៀម** ស្នើសុំអន្តរាគមន៍ជួយបង្កើតគណៈកម្មការចម្រុះថ្នាក់ខេត្ត និងចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំ អង្កេត និងសុំកាត់ឆ្វៀលដីទំហំ ៨០ហិកតា ចេញពីតំបន់គម្របព្រៃឈើ ដើម្បីចុះបញ្ជីក្បាលដី កសាងប័ណ្ណកម្មសិទ្ធិ និងផ្លាស់ប្តូរប័ណ្ណកម្មសិទ្ធិថ្មី ស្ថិតនៅភូមិអូរគគីរ ឃុំបិតត្រាំង, ភូមិចំការកៅស៊ូ ឃុំជើងគោ និងភូមិអូរត្រជាក់ចិត្ត ឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

- ឈ្មោះ **ដាន គី,ស៊ីវ អេង,សេង ចាយ** និងឈ្មោះ**អៀវ ហ៊ួយ** ស្នើសុំអន្តរាគមន៍ជួយបង្កើតគណៈកម្មការចម្រុះថ្នាក់ខេត្ត និងចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំងវាស់វែង កំណត់ព្រំ អង្កេត និងសុំកាត់ឆ្វៀលដីទំហំ២៥០ហិកតា ចេញពីតំបន់គម្របព្រៃឈើ ដើម្បីចុះបញ្ជីក្បាលដីកសាងប័ណ្ណកម្មសិទ្ធិ និងផ្លាស់ប្តូរប័ណ្ណកម្មសិទ្ធិថ្មីស្ថិតនៅភូមិ០៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

-រដ្ឋបាលខេត្តមណ្ឌលគិរី ករណីៈ

- គណនីឈ្មោះ **Kheng Lee** ផ្ញើសារចូលក្នុងគេហទំព័រហ្វេសប៊ុករបស់ សម្តេចក្រឡាហោម ពាក់ព័ន្ធនឹងករណីថ្នាក់ដឹកនាំខេត្តមណ្ឌលគិរី ឃុបឃិតគ្នាជាប្រព័ន្ធកាត់យកដីប្រជាពលរដ្ឋដោយចោទប្រកាន់ថាជាដីក្នុងដែនជម្រកដែលរដ្ឋកាន់កាប់។

• គណនីឈ្មោះ Khunly Heng ផ្ញើសារចូលក្នុងគេហទំព័រហ្វេសប៊ុករបស់សម្តេចក្រឡាហោម ពាក់ព័ន្ធនឹងករណីការទិញលក់ដីធ្លី និងរំលោភលើសេចក្តីទុកចិត្តដែលមានទីតាំងនៅភូមិពូរ៉ាង ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្ត មណ្ឌលគិរី ពីលោក ធូ សេងង៉ាន់ ជាអនុប្រធានមន្ទីរចាត់ការ នៃបណ្ឌិត្យសភានគរបាលកម្ពុជា។

-រដ្ឋបាលខេត្តកោះកុង ករណី៖

• គណនីឈ្មោះ Sunly Kuong ផ្ញើសារចូលក្នុងគេហទំព័រហ្វេសប៊ុករបស់ សម្តេចក្រឡាហោម ពាក់ព័ន្ធនឹងឈ្មោះ លីម បុក ជាមន្ត្រីកងរាជអាវុធហត្ថ បានប្រើអំណាចធ្វើការបូមដីខ្សាច់ នៅក្នុងព្រែកស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង និងធ្វើការប្រមូលលុយពីប្រជាពលរដ្ឋតាមដងព្រែកដែលធ្វើការបូមដីខ្សាច់យកប្រើប្រាស់។

• គណនីឈ្មោះ សម្រស់កោះកុង ផ្ញើសារចូលក្នុងគេហទំព័រហ្វេសប៊ុករបស់ សម្តេចក្រឡាហោម ពាក់ព័ន្ធនឹងករណីវិវាទដីធ្លីរវាងប្រជាពលរដ្ឋ ស្ថិតនៅភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

• បានធ្វើលិខិតឆ្លើយតបទៅតំណាងប្រជាពលរដ្ឋ ១៧៥គ្រួសារ ដែលបានប្តឹងឈ្មោះ ឆាយ រី ពីបទញុះញង់ប្រជាពលរដ្ឋឱ្យលក់ដីបម្រុងទុករបស់សហគមន៍ ១៧៥គ្រួសារ ចំនួន ៨៤ឡូតិ៍ ស្មើនឹងទំហំ ១៣២ហិកតា នៅចំណុចព្រៃពោង វត្តគងធា(ប៥) ភូមិជីខ ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង។

-ស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា ករណីឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជាស្នើជួបប្រជុំជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តតាកែវ។

-អគ្គស្នងការដ្ឋាននគរបាលជាតិ ករណីសំណើសុំធ្លាក់ត្រាមូលទឹកថ្មីរបស់រដ្ឋបាលខណ្ឌ៧មករា និងសង្កាត់ទាំង០៨ ក្នុងមូលដ្ឋានខណ្ឌ៧មករា នៃរដ្ឋបាលរាជធានីភ្នំពេញចំនួន ០៩គ្រឿង។

-អង្គការអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ករណីស្នើសុំធ្វើការបំភ្លឺតបនឹងលិខិតលេខ ៦០៨/១៩សជណ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ ពាក់ព័ន្ធនឹងសកម្មភាព និងបញ្ហាគ្រប់គ្រងកាន់កាប់ដីរបស់អង្គការអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ស្ថិតនៅភូមិបឹងស្នោ ឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

-ខេត្តកំពង់ឆ្នាំង ករណីជនល្មើសលួចឈូសឆាយ កាប់ព្រៃ បោះបង្គោល និងសង់ខ្ទមចូលដែនជម្រកសត្វព្រៃឱរ៉ាល់ ស្ថិតក្នុងឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

- ខេត្តស្ទឹងត្រែង ក្រចេះ ព្រះវិហារ មណ្ឌលគិរី និងខេត្តរតនគិរី ករណីអំពីការតែងតាំងអគ្គកុងស៊ុលឡាវថ្មីនៅខេត្តស្ទឹងត្រែង។

### ៧.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន ០១ ខេត្ត២៤ ក្រុង២៧ ស្រុក១៦២ ខណ្ឌ១៤ ឃុំ១.៤០៥ សង្កាត់២៤១ និងភូមិចំនួន ១៤.៣៨៤។

-ខេត្តរតនគិរី និងខេត្តកែប បានរៀបចំប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវនិមិត្តសញ្ញារបស់រដ្ឋបាលខេត្តរតនគិរី និងខេត្តកែប។

### ៧.៣-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ

ក្រសួងមហាផ្ទៃ បានលើកសំណើជូនរាជរដ្ឋាភិបាលកម្ពុជា ករណីស្នើសុំគោរមងារជាឧកញ៉ា ចំនួន០៤រូប មេដាយជាតូបការ ចំនួន ០៤គ្រឿង មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០១គ្រឿង ដើម្បីផ្តល់ជូនសប្បុរសជនដែលបានជួយកសាងសមិទ្ធផលជាច្រើននៅក្នុងខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ និងខេត្តព្រៃវែង ដោយចំណាយអស់ថវិកាសរុបចំនួន ២.២២៦.១០៣ដុល្លារ (ពីរលានពីររយម្ភៃប្រាំមួយពាន់មួយរយបីដុល្លារសហរដ្ឋអាមេរិក)(ដូចក្នុងឧបសម្ព័ន្ធ៣)។

### ៧.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា

#### ៧.៤.១-កម្មវិធីគាំទ្រដោយអង្គការសហប្រជាជាតិសម្រាប់កុមារ UNICEF

-រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិលើសេចក្តីព្រាងកែសម្រួលសេចក្តីណែនាំស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

- ប្រជុំពិនិត្យ ពិភាក្សាលើការរៀបចំកែសម្រួលសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរដ្ឋបាលថ្នាក់ក្រោមជាតិ។

- ប្រជុំពិភាក្សាលើការរៀបចំប្រព័ន្ធទិន្នន័យគម្រោងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

#### ៧.៤.២-គម្រោងសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP

គិតត្រឹមខែមិថុនា ឆ្នាំ២០២០នេះ ការវិវឌ្ឍនៃដំណើរការការដ្ឋានសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់គិតជារួមបានប្រមាណ៧៥ភាគរយ ។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានចាត់មន្ត្រី៖

-ចុះពិនិត្យតាមដានដំណើរការសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ ដំណាក់កាលទី១ ទី២ និងទី៣។

-ចុះពិនិត្យការដ្ឋានសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ដែលបានបញ្ចប់ការសាងសង់ដើម្បីត្រៀមរៀបចំពិធីប្រគល់-ទទួល។

-បានប្រគល់-ទទួល នូវអគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុកចំនួន ០៣ និងឃុំចំនួន ១០ ក្នុងខេត្តកណ្តាល ។

### ៧.៥-ការងារគម្រោងមូលនិធិ និងការគាំទ្រក្រុង ស្រុក ឃុំ សង្កាត់

#### ៧.៥.១-គម្រោងក្រុង ស្រុក

ការរៀបចំគម្រោងក្រុង ស្រុក ឆ្នាំ២០២០ មានចំនួន ៤២៨គម្រោង ដែលក្នុងនោះ៖ គម្រោងមិនទាន់សិក្សាចំនួន **១៤៤គម្រោង** (ស្មើនឹង៣៣.៦៤%) គម្រោងកំពុងដំណើរការសិក្សាចំនួន **១៤០គម្រោង** (ស្មើនឹង៣២.៧២%) និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **១៤៤គម្រោង**(ស្មើនឹង៣៣.៦៤%)ហើយក្នុងចំណោមគម្រោងដែលបានបញ្ចប់ការសិក្សាមានគម្រោងចំនួន **៥៨គម្រោង**(ស្មើនឹង៤០.២៨%)បានដេញថ្លៃរួចរាល់។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០២០ មានចំនួន **២៥កិច្ចសន្យា** ក្នុងនោះរួមមាន៖ បញ្ចប់ការសាងសង់១០០% ចំនួន **០៣កិច្ចសន្យា**(ស្មើនឹង ១២%) អនុវត្តបានតិចជាង៥០% ចំនួន **០២កិច្ចសន្យា**(ស្មើនឹង ៨%)និងមិនទាន់បានអនុវត្តចំនួន **២០កិច្ចសន្យា**(ស្មើនឹង៨០%)។ ជាមួយគ្នានេះដែរ សំណើគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០១៩មានចំនួន **៥៣៥គម្រោង** ដែលក្នុងនោះ៖គម្រោងមិនទាន់សិក្សាចំនួន **២៩គម្រោង**(ស្មើនឹង៥,៤២%) គម្រោងកំពុងដំណើរការសិក្សាចំនួន **០៦គម្រោង**(ស្មើនឹង១.១២%) និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **៥០០គម្រោង**(ស្មើនឹង៩៤.៤៦%) ហើយបានដេញថ្លៃរួចចំនួន **៥០០** គម្រោង(ស្មើនឹង១០០%) នៃគម្រោងដែលបានបញ្ចប់ការសិក្សា។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងក្រុង ស្រុកឆ្នាំ២០១៩មានចំនួន **៤៩៩កិច្ចសន្យា** ក្នុងនោះរួមមាន៖ បញ្ចប់ការសាងសង់១០០% ចំនួន **៤៦៥** កិច្ចសន្យា(ស្មើនឹង៩៣.១៩%) អនុវត្តបានលើស៥០% ចំនួន **១៧កិច្ចសន្យា** (ស្មើនឹង៣.៤១%)អនុវត្តបានតិចជាង៥០%ចំនួន**១១កិច្ចសន្យា**(ស្មើនឹង២.២០%) និងមិនទាន់បានអនុវត្តចំនួន ០៦កិច្ចសន្យា(ស្មើនឹង១.២០%)។

#### ៧.៥.២-គម្រោងមូលនិធិឃុំ សង្កាត់

ការរៀបចំគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២០ មានចំនួន **១.៩៥២គម្រោង**( ក្នុងនោះកំពុងដំណើរការសិក្សាចំនួន ៨៤៥គម្រោង(ស្មើនឹង៤៣,២៩%) មិនទាន់ចាប់ផ្តើមសិក្សាចំនួន **២៤០គម្រោង**(ស្មើនឹង១២,៣០%) និងបានបញ្ចប់ការសិក្សាចំនួន ៨៦៧គម្រោង(ស្មើនឹង៤៤.៤១%) ហើយបានដេញថ្លៃរួចរាល់ចំនួន **២០៨គម្រោង** (ស្មើនឹង២៣.៩៩%) នៃគម្រោងដែលបានបញ្ចប់ការសិក្សា។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ២០២០សរុបចំនួន ៩៦កិច្ចសន្យា ក្នុងនោះរួមមាន៖ ការអនុវត្តបានលើសពី៥០%ចំនួន

២៧កិច្ចសន្យា(ស្មើនឹង២៨.១៣%) អនុវត្តបានតិចជាង៥០%ចំនួន ១៧កិច្ចសន្យា (ស្មើនឹង១៧.៧១%)និង មិនទាន់បានអនុវត្តចំនួន ៣៤កិច្ចសន្យា (ស្មើនឹង ៣៥.៤២%) ។ ដោយឡែកការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៩មានចំនួន ១.៨០៦គម្រោង (ក្នុងនោះបញ្ចប់ការសិក្សាចំនួន១.៨០៦គម្រោង(ស្មើនឹង១០០%) និងបាន ដេញថ្លៃរួចរាល់ចំនួន ១៧៩១គម្រោង(ស្មើនឹង ៩៩.១៧%)។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោង មូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៩មានចំនួន១.៧៨៦កិច្ចសន្យា ក្នុងនោះរួមមាន៖ ការអនុវត្តបានលើសពី៥០% ចំនួន ១៥៤កិច្ចសន្យា(ស្មើនឹង៨.៦២%)ការអនុវត្តបានតិចជាង៥០%ចំនួន៧១កិច្ចសន្យា(ស្មើនឹង៣.៩៨%) បញ្ចប់ ការសាងសង់១០០%ចំនួន ១.៥៤៦កិច្ចសន្យា(ស្មើនឹង៨៦.៥៦%)និងមិនទាន់បានអនុវត្តចំនួន ១៥កិច្ចសន្យា (ស្មើនឹង០.៨៤%)។

**៧.៦-ការផ្តល់សេវា និងការដោះស្រាយវិវាទនៅមូលដ្ឋាន**

**៧.៦.១-ការផ្ទេរមុខងារ និងធនធាន**

-ចូលរួមកិច្ចប្រជុំពិភាក្សាជាមួយនឹងលេខាធិការដ្ឋានគ.ជ.អ.ប និងក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវ-នីតិសម្បទា ស្តីពីការប្រមូលទិន្នន័យទ្រព្យសម្បត្តិរបស់មណ្ឌលកុមារកំព្រារបស់រដ្ឋ ដែលត្រូវផ្ទេរពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្តទៅឱ្យរដ្ឋបាលរាជធានី ខេត្តសម្រាប់អនុវត្តមុខងារគ្រប់គ្រងមណ្ឌល កុមារកំព្រារបស់រដ្ឋ

-បានចូលរួមកិច្ចប្រជុំពិភាក្សាជាមួយនឹងលេខាធិការដ្ឋានគ.ជ.អ.ប ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្ទេរទ្រព្យសម្បត្តិរបស់មន្ទីរសុខាភិបាលរាជធានី ខេត្តទៅឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ រដ្ឋបាលរាជធានី ខេត្ត

-បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការអនុវត្តការផ្ទេរសេវាពីមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្តទៅ អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងការផ្ទេរមុខងារទៅការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ នៅក្រសួងសាធារណការ និងដឹកជញ្ជូន

-បានចូលរួមក្នុងកិច្ចប្រជុំអនុក្រុមការងារបច្ចេកទេសផ្នែកដឹកជញ្ជូនតាមផ្លូវគោក ដើម្បីពិនិត្យ និងរៀបចំនីតិ វិធីផ្ទេរសេវាដឹកជញ្ជូនផ្លូវគោកមកអនុវត្តតាមយន្តការច្រកចេញចូលតែមួយ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៧.៦.២-ការផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយ**

**ក.ការផ្តល់សេវាតាមរយៈអង្គភាពច្រកចេញចូលតែមួយ**

ក្នុងខែមិថុនាឆ្នាំ២០២០នេះ អង្គភាពច្រកចេញចូលតែមួយទាំង២៥រាជធានី ខេត្តបានផ្តល់សេវារដ្ឋបាល សរុបចំនួន ៤២.៧៥៨សេវា ក្នុងនោះបើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង១៤ ឃើញថា **វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**ផ្តល់សេវាបានច្រើនជាងគេគឺចំនួន ១៨.២៥៧សេវា(ស្មើនឹង ៤២,៧០%) បន្ទាប់មកវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ៩.៨៩១សេវា (ស្មើនឹង២៣.១៣%) ចំពោះវិស័យវប្បធម៌ផ្តល់សេវាបានតិចជាងគេគឺចំនួន ០១សេវា (ស្មើនឹង០.០០២%)(**ដូចក្នុងឧបសម្ព័ន្ធ៤**)។ ជាមួយគ្នានេះដែរ អង្គភាពច្រកចេញចូលតែមួយទាំង ២៥រាជធានី ខេត្តទទួលបានចំណូលសរុបចំនួន៦.៣៥០ .៥១៩.០៨៦រៀល (ស្មើនឹង១.៥៨៧.៦២៩,៧៧១ដុល្លាអាមេរិក) ក្នុងនោះបើប្រៀបធៀបចំណូលដែលទទួល បាននៅក្នុងចំណោមវិស័យទាំង១៤ ឃើញថា **វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**ទទួលបានចំណូល ខ្ពស់ជាងគេគឺចំនួន ៤.៨៨៤.២៧០.៥៣៦រៀល (ស្មើនឹង៧៦,៩១%)បន្ទាប់មកវិស័យសាធារណការ និងដឹក ជញ្ជូនទទួលបានចំណូលចំនួន ៥៩៧.៤០៣.៥០០រៀល (ស្មើនឹង ៨,៧៨%) ។ ចំពោះវិស័យវប្បធម៌ និងវិចិត្រ សិល្បៈទទួលបានចំណូលតិចជាងគេគឺចំនួន ២០០.០០០រៀល(ស្មើនឹង០,០៣%)(**ដូចក្នុងឧបសម្ព័ន្ធ៥**)។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តសកម្មភាពមួយចំនួន ដើម្បីគាំទ្រដល់អង្គភាពច្រកចេញចូល តែមួយដូចខាងក្រោម៖

-បានពិនិត្យ និងផ្តល់យោបល់លើការរៀបចំសារាចរណែនាំស្តីពីនីតិវិធីកត់ត្រា និងកិច្ចបញ្ជីកា នៃការអនុ-វត្តចំណូលសេវារបស់អង្គភាព ច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលសេវា ដែលផ្តល់នៅមន្ទីរជំនាញ រាជធានី ខេត្ត នៃ អនុក្រឹត្យលេខ ២៥អនក្រ.បក ចុះថ្ងៃទី០៩ខែមីនា ឆ្នាំ២០២០

-បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ និងចែករំលែកបទពិសោធន៍អំពីការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត នៅសាលប្រជុំសាលាខេត្តត្បូងឃ្មុំ

-បានចេញលិខិតឆ្លើយតបទៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ស្តីពីដំណើរការនៃការផ្តល់សេវាត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ)

-បានរៀបចំកិច្ចប្រជុំលើកទី៣របស់ក្រុមការងាររៀបចំកម្មវិធីព័ត៌មានវិទ្យា សម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-បានរៀបចំកិច្ចប្រជុំពិនិត្យពាក្យស្នើសុំ ទម្រង់បែបបទក្នុងវិស័យសាធារណការ ដឹកជញ្ជូនផ្លូវទឹក និងផ្លូវគោក សម្រាប់ការផ្តល់សេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-បានរៀបចំកិច្ចប្រជុំជាមួយក្រុមការងារបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីនីតិវិធី ទម្រង់បែបបទ និងលក្ខខណ្ឌភ្ជាប់នានាក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ផ្តល់សេវានៅអង្គភាពច្រកចេញចូលតែមួយ។

**ខ.ការផ្តល់សេវាតាមរយៈការិយាល័យច្រកចេញចូលតែមួយ**

ក្នុងខែមិថុនា ឆ្នាំ២០២០នេះ ក្នុងចំណោមការិយាល័យច្រកចេញចូលតែមួយចំនួន ១១៥គោលដៅ មានការិយាល័យច្រកចេញចូលតែមួយចំនួន ៩៤គោលដៅ បានផ្តល់សេវារដ្ឋបាលសរុបចំនួន ១៤៩.០៦៨សេវា បើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង១៤ ឃើញថា **វិស័យនីត្យានុកូលកម្ម**បានផ្តល់សេវាបានច្រើនជាងគេគឺចំនួន **១០៨.៤៦៦សេវា** (ស្មើនឹង **៧២.៧៦%**) បន្ទាប់មក**វិស័យអគ្គានុកូលដ្ឋាន**ចំនួន **២៨.២៧៧ សេវា** (ស្មើនឹង **១៨.៩៧%**) ចំពោះវិស័យដែលមិនបានផ្តល់សេវាគឺ **វិស័យរ៉ែ និងថាមពល(ដូចក្នុងឧបសម្ព័ន្ធ៦)**។ យ:ពេលដូចគ្នានេះដែរ ក្នុងចំណោមការិយាល័យច្រកចេញចូលតែមួយទាំង ១១៥គោលដៅ មានការិយាល័យច្រកចេញចូលតែមួយចំនួន ៩៤គោលដៅទទួលបានប្រាក់ចំណូលសរុបចំនួន ១.២០៧.៤៩៤.៩៤០រៀល (ស្មើនឹង ៣០១.៨៧៣,៧៣៥ដុល្លារអាមេរិក) បើប្រៀបធៀបចំណូលដែលទទួលបានពីវិស័យទាំង១៤ឃើញថា **វិស័យសុរិយោដី**មានចំណូលខ្ពស់ជាងគេគឺចំនួន **៦៤២.៨០៤.០០០រៀល** (ស្មើនឹង **៥៣.២៣%**) បន្ទាប់មក **វិស័យសំណង់** ទទួលបានចំណូលចំនួន **២២២.៣៤៤.០០០រៀល**(ស្មើនឹង **១៨.៤១%**) ចំពោះវិស័យដែលមិនទទួលបានចំណូលគឺ**វិស័យរ៉ែ និងថាមពល(ដូចក្នុងឧបសម្ព័ន្ធ៧)**។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តសកម្មភាពមួយចំនួន ដើម្បីគាំទ្រដល់ការិយាល័យច្រកចេញចូលតែមួយដូចខាងក្រោម៖

-បានពិនិត្យ និងផ្តល់យោបល់លើសារាចរណែនាំស្តីពីនីតិវិធីកត់ត្រា និងកិច្ចបញ្ជីកា នៃការអនុវត្តចំណូលសេវារបស់អង្គភាព ច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលសេវា ដែលផ្តល់នៅមន្ទីរជំនាញរាជធានី ខេត្ត នៃ អនុក្រឹត្រលេខ ២៥អនក្រ.បក ចុះថ្ងៃទី០៩ខែមីនា ឆ្នាំ២០២០

-រៀបចំកិច្ចប្រជុំពិនិត្យមើលទម្រង់បែបបទ និងនីតិវិធីនៃការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយក្រុងស្រុក ខណ្ឌ ក្នុងវិស័យសាធារណការ និងដឹកជញ្ជូន វិស័យរ៉ែ និងថាមពល និងវិស័យឧស្សាហកម្ម

-បានចាត់តាំងក្រុមការងារចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យនៅខេត្តសៀមរាប

-បានចូលរួមកម្មវិធីបណ្តុះបណ្តាលការផ្តល់សេវាចុះបញ្ជីទោចក្រយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងការបំពាក់សម្ភារសម្រាប់ការចុះបញ្ជីទោចក្រយានយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដល់ខណ្ឌគោលដៅ ថ្មីចំនួនពីរ គឺខណ្ឌបឹងកេងកង និងខណ្ឌកំបូល។

**៧.៦.៣-ការដោះស្រាយវិវាទរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

**ក).ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត**

ក្នុងខែមិថុនា ឆ្នាំ២០២០នេះ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តទាំង២៥គោលដៅបានទទួលបណ្តឹង សំណូមពរ ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងមិនពាក់ព័ន្ធសរុបចំនួន

៦៧ករណី ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន ១៦ករណី(បញ្ចប់ការដោះស្រាយ ០៩ករណី កំពុងដោះស្រាយ ០៧ករណី) បណ្តឹងក្រៅសមត្ថកិច្ចចំនួន ២៣ករណី ការសរសើរចំនួន ០១ករណី សំណូមពរចំនួន ១៥ករណី និងការសាកសួរព័ត៌មានចំនួន ១២ករណី។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាល បានរៀបចំវគ្គតម្រង់ទិស ស្តីពីនីតិវិធីសម្រុះសម្រួលដោះស្រាយបណ្តឹង និងកត់ត្រាបណ្តឹងនៅគុពិសេសរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តនៅខេត្តកំពតចំនួន២វគ្គរយៈពេល៤ថ្ងៃ។

**ខ).ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ**

ក្នុងខែមិថុនា ឆ្នាំ២០២០នេះ ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌទាំង៩៤គោលដៅក្នុងចំណោម១១៥គោលដៅបានទទួលបណ្តឹង សំណូមពរ ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធនិងមិនពាក់ព័ន្ធសរុបចំនួន៨១៤ករណី ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន ១២ករណី (បញ្ចប់ការដោះស្រាយ ១១ករណី កំពុងដោះស្រាយ ០១ករណី) និងបណ្តឹងក្រៅសមត្ថកិច្ចចំនួន ១២ករណី ការសរសើរចំនួន ២៦ករណី សំណូមពរចំនួន ៤១ករណី ការសាកសួរព័ត៌មានផ្សេងៗចំនួន ៧២៣ករណី។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាល បានដាក់ចេញប្រកាសទទួលស្គាល់ប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុកដែលនៅសេសសល់ចំនួន៣គោលដៅ ក្នុងចំណោម ៣២គោលដៅ ឆ្នាំ២០១៩ រួមមាន៖ ស្រុកបន្ទាយស្រី ក្រុងកោះរ៉ុង និងស្រុកកូនក្រៀង។

**៨-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

ក្នុងខែមិថុនា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានធ្វើលិខិតជម្រាបជូនទៅក្រសួង ស្ថាប័ន អង្គភាពនានាដូចខាងក្រោម៖

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ករណីក្រសួងមហាផ្ទៃចាត់តាំងឯកឧត្តម សួស ប្រាថ្នា អគ្គនាយករងទទួលបន្ទុកជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត ចូលរួមក្នុងក្រុមការងារបច្ចេកទេសអន្តរក្រសួងសិក្សា និងកសាងផែនការរៀបចំដែនដីថ្នាក់ជាតិ។

- ក្រសួងសាធារណការ និងដឹកជញ្ជូន ករណីសុំផ្តល់ស្លាកលេខសម្គាល់យានយន្តរបស់អង្គការចំនួន១

-ក្រសួងរ៉ែ និងថាមពល ស្នើសុំយោបល់ចំពោះការស្នើសុំចុះឈ្មោះអង្គការស្រាវជ្រាវ និងអភិវឌ្ឍន៍ភូគព្ភសាស្ត្រកម្ពុជា។

- ក្រសួង-ស្ថាប័នពាក់ព័ន្ធ ករណីស្នើសុំចាត់មន្ត្រីជំនាញបច្ចេកទេស(ថ្នាក់ប្រធាននាយកដ្ឋានឡើង) ដើម្បីចូលរួមកិច្ចប្រជុំពិភាក្សាអំពីគម្រោងកម្មវិធីការពារពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ និងសហគមន៍ពីហានិភ័យឆ្លងជំងឺកូវីដ១៩ទ្រង់ទ្រាយធំ និងការផ្តល់សេវាចាំបាច់នានានៅមូលដ្ឋានកាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ក្រោមអធិបតីភាពឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ។

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ករណីសំណើសុំអញ្ជើញ ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកណ្តាល និងខេត្តតាកែវ ចូលរួមអមដំណើរ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ចុះពិនិត្យអាកាសយានដ្ឋានថ្មី ស្ថិតនៅភូមិសាស្ត្រស្រុកកណ្តាលស្ទឹង និងស្រុកស្អាង ខេត្តកណ្តាល និងភូមិសាស្ត្រ ស្រុកបាទី ខេត្តតាកែវ។

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ករណីសំណើសុំអញ្ជើញអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ចូលរួមពិធីប្រកាសដាក់ឲដំណើរការជាផ្លូវការ "កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-១៩ នៅសាលរដ្ឋសភា វិមានសន្តិភាព។

-ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ករណីស្នើសុំអនុញ្ញាតជាគោលការណ៍ឱ្យអ្នកជំនាញការផ្នែកសិក្សាស្រាវជ្រាវចុះអង្កេតស្តីពី"ការស្វែងយល់ទស្សនៈសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជា៖ ចំណេះដឹង ឥរិយាបថ និងការអនុវត្តលើកទី៣"។

-អគ្គស្នងការដ្ឋាននគរបាលជាតិ ករណីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ស្នើសុំបង្កើតត្រារបស់ការិយាល័យច្រកចេញចូលតែមួយ និងវិទ្យាស្ថានវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍។

-វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ករណីស្នើសុំចុះធ្វើអង្កេតសម្រាប់ការសិក្សាស្រាវជ្រាវស្តីពីគម្រោង "ការវិភាគទស្សនៈយេនឌ័រលើភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងអាហារូបត្ថម្ភ ប្រទេសកម្ពុជា និងប្រទេសឥណ្ឌាភាគខាងត្បូង" និងគម្រោង "ការវិភាគយេនឌ័រ និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ននៅប្រទេសកម្ពុជា"។

**៩.ការងារតាមវិស័យផ្សេងៗ**

**៩.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងប័ណ្ណព្រំដែន**

**ក.ការងារច្រកទ្វារព្រំដែន**

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានច្រកទ្វារព្រំដែនសរុបចំនួន ៨២ច្រក រួមមានច្រកទ្វារកំពង់ផែអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារព្រំដែនអន្តរជាតិចំនួន ២៦ច្រក ច្រកទ្វារព្រំដែនទ្វេភាគីចំនួន ១៤ច្រក ច្រកទ្វារតំបន់ព្រំដែនចំនួន ២៦ច្រក និងច្រកទ្វារកំពង់ផែសមុទ្រចំនួន ១០ច្រក។

- ចុះសិក្សា ពិនិត្យ វាយតម្លៃចំពោះសំណើរដ្ឋបាលខេត្តកំពត ស្នើសុំបង្កើតច្រកទ្វារព្រំដែនថ្មី ចំនួន ០២ ស្ថិតនៅក្នុងស្រុកបន្ទាយមាស ខេត្តកំពត។
- បានរៀបចំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងកិច្ចព្រមព្រៀងសាងសង់ស្ពានថ្មីនៅច្រកទ្វារព្រំដែនអន្តរ-ជាតិព្រំ(ប៉ៃលិន)-បានផាកកាដ(ច័ន្ទបុរី) នៅទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ។
- បានស្នើរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ទាំងអស់ផ្តល់បច្ចុប្បន្នភាពនៃការបោះតង់និងប៉ុស្តិ៍យាមរបស់ភាគីវៀតណាមនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាមក្រោមរូបភាពការពារជំងឺកូវីដ១៩។

**ខ.ការងារប័ណ្ណព្រំដែន**

គិតចាប់ពីថ្ងៃទី១៩ ខែឧសភា ដល់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃបានផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋប្រើប្រាស់ជាផ្លូវការសរុបចំនួន ៣៦៤ប័ណ្ណ(ក្នុងនោះខេត្តបាត់ដំបង១៤៨ប័ណ្ណ ខេត្តបន្ទាយមានជ័យ១២០ប័ណ្ណ ខេត្តឧត្តរមានជ័យ៤៩ប័ណ្ណ ខេត្តប៉ៃលិន២៩ប័ណ្ណ និងខេត្តកោះកុងចំនួន ១៨ប័ណ្ណ)។ រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ បានធ្វើការបន្តសុពលភាពប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋ ដើម្បីចេញចូលឆ្លងកាត់ព្រំដែនកម្ពុជា-ថៃបានចំនួន ១៦ប័ណ្ណ។

**៩.២-ការងារចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ដើម្បីបង្កើនទំនាក់ទំនង ចងសម្ព័ន្ធមេត្រីភាពជាមិត្តភាព និងសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានាជាមិត្ត ក្រសួងមហាផ្ទៃបានធ្វើលិខិតគោរពទៅក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្ត រាជធានីដូចខាងក្រោម៖

-រដ្ឋបាលរាជធានីភ្នំពេញ ករណីស្ថានទូតរុស្ស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា ស្នើសុំជួយធានាសន្តិសុខនៅតំបន់ជុំវិញស្ថានទូត។

-រដ្ឋបាលខេត្តស្ទឹងត្រែង ក្រចេះ ព្រះវិហារ មណ្ឌលគិរី និងខេត្តរតនគិរី ករណីអំពីការតែងតាំងអគ្គកុងស៊ុលឡាវថ្មី នៅខេត្តស្ទឹងត្រែង។

**៩.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ**

ក្នុងខែមិថុនា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាល បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច លើសំណើសុំផ្តល់អនុលោមភាពលើគម្រោងអភិវឌ្ឍន៍ឆ្នាំ២០២០ចំនួន ៤២គម្រោងរបស់រដ្ឋបាលខេត្តចំនួន ០៧ រួមមាន៖ ខេត្តព្រះសីហនុ(៤គម្រោង) ខេត្តកំពង់ចាម(១១គម្រោង) ខេត្តក្រចេះ(៣គម្រោង) ខេត្តត្បូងឃ្មុំ(៣គម្រោង) ខេត្តតាកែវ(៩គម្រោង) ខេត្តបាត់ដំបង(១០គម្រោង)និងខេត្តស្ទឹងត្រែង(២គម្រោង)

មានទឹកប្រាក់សរុបចំនួន ៤៣.០៦៥.៣៨៦.៦៨២រៀល (សែសិបបីប៊ីលានហុកសិបប្រាំលានប្រាំមួយរយប៉ែតសិបពីរពាន់រៀលគត់)(ដូចក្នុងឧបសម្ព័ន៨) និងគម្រោងអភិវឌ្ឍន៍ឆ្នាំ២០១៩ចំនួន១៩គម្រោង របស់រដ្ឋបាលខេត្តព្រះវិហារមានទឹកប្រាក់សរុបចំនួន ៣៧.៦២៩.៩០០.០០០រៀល (សាមសិបប្រាំពីរប៊ីលានប្រាំមួយរយម្ភៃប្រាំបួនលានប្រាំបួនរយពាន់រៀលគត់(ដូចក្នុងឧបសម្ព័ន្ធ ៩) ។ ជាមួយគ្នានេះថ្នាក់ដឹកនាំបានសម្រេចផ្តល់អនុលោមភាពផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ(២០២០-២០២៤) អាណិត្តទី៣របស់ក្រុមប្រឹក្សាខេត្តរតនគិរី ខេត្តតាកែវ និងខេត្តក្រចេះ។ ទន្ទឹមនោះ អគ្គនាយកដ្ឋានរដ្ឋបាល បានអនុវត្តសកម្មភាពមួយចំនួន ដើម្បីគាំទ្រដល់ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យដូចខាងក្រោម៖

-បានពិនិត្យ និងលើកយោបល់ ជូនថ្នាក់ដឹកនាំលើសំណើសុំផ្តល់អនុលោមភាពផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំអាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្តកំពត ស្ទឹងត្រែង ព្រះវិហារ ត្បូងឃ្មុំ និងខេត្តកែប។

-បានធ្វើលិខិតក្នុងនាមក្រសួងមហាផ្ទៃជម្រាបទៅរដ្ឋបាលរាជធានី ខេត្ត ស្តីពីការចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងអភិវឌ្ឍបញ្ចប់ឆ្នាំ២០១៩ របស់រដ្ឋបាលរាជធានី ខេត្ត។

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ករណីរដ្ឋបាលរាជធានីភ្នំពេញ ស្នើសុំធ្វើអនុបយោគដីចំនួន ០៣ទីតាំង និងពិនិត្យសម្រេចលើការប្តូរទីតាំងមូលដ្ឋានកងរាជអាវុធហត្ថខណ្ឌដូនពេញ ទីតាំងប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ចតុមុខ និងទីតាំងបន្ទប់ទឹកសាធារណៈ ស្ថិតនៅសង្កាត់ចតុមុខ ខណ្ឌដូនពេញ ទៅកាន់ទីតាំងថ្មី និងផ្តល់ជាកម្មសិទ្ធិជូនលោកជំទាវឧកញ៉ា ជឹង សុភាព។

-រដ្ឋបាលខេត្តកណ្តាល ករណីសំណើសុំជួលទីតាំងដីទំហំ ១៨៣ហិកតា ស្ថិតនៅឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដើម្បីបង្កើតជាតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ពាណិជ្ជកម្មពហុបំណង របស់ក្រុមហ៊ុនអាណាចក្រឌីវេឡុបមេន គ្រុប។

-រដ្ឋបាលខេត្តកំពង់ឆ្នាំង ករណីស្នើសុំចុះកិច្ចសន្យាជាមួយក្រុមហ៊ុន វីសាន់ ឌីវេឡុបមិន អេឡិចទ្រីស៊ីធី ស្តីពីការផ្គត់ផ្គង់ ថែទាំ និងប្រតិបត្តិការសេវាប្រព័ន្ធភ្លើងបំភ្លឺសាធារណៈ។

### ៩.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ

#### ៩.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

គិតមកដល់បច្ចុប្បន្នសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះឈ្មោះក្នុងបញ្ជី នៅក្រសួងមហាផ្ទៃសរុបចំនួន ៥.៦៧១(ក្នុងនោះសមាគមចំនួន ២.៣២១ អង្គការមិនមែនរដ្ឋាភិបាលចំនួន ៣.៣៥០) និងសហគមន៍ជនជាតិដើមភាគតិចចំនួន១៤៧ (ដូចក្នុងឧបសម្ព័ន្ធ១១)។ ក្នុងខែមិថុនា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានសម្រេចចុះបញ្ជីសមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ជនជាតិដើមភាគតិចចំនួន ១៥(ក្នុងនោះសមាគម ៩ អង្គការមិនមែនរដ្ឋាភិបាល ៣ និងសមាគមន៍ជនជាតិដើមភាគតិចចំនួន ៣)(ដូចក្នុងឧបសម្ព័ន្ធ១១)។

ទន្ទឹមនេះ ក៏បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេចពាក់ព័ន្ធនឹងការងារនានា ដូចជាការសុំចុះឈ្មោះក្នុងបញ្ជីសមាគម អង្គការមិនមែនរដ្ឋាភិបាល ការសុំទទួលស្គាល់ប្រធាន ការសុំផ្លាស់ប្តូរសមាសភាពថ្មី នៃវេចនាសម្ព័ន្ធ ការសុំធ្វើវិសោធនកម្មលក្ខន្តិកៈ ការសុំបើកទីស្នាក់ការសាខា ការសុំប្តូរឈ្មោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការលុបឈ្មោះ ការផ្អាកសកម្មភាពបណ្តោះអាសន្នចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។ លើសពីនេះ ក្រសួងមហាផ្ទៃបានសម្រេចផ្អាកសកម្មភាពបណ្តោះអាសន្នរយៈពេល៣០ថ្ងៃ ចំពោះសមាគមមូលនិធិទ្រទ្រង់សមាគមកម្ពុជា ព្រមទាំងបានបញ្ចូលទិន្នន័យស្តេនសំណុំឯកសារពាក់ព័ន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ២៣ច្បាប់ ក្នុងនោះសមាគមចំនួន ១៣ច្បាប់ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១០ច្បាប់។

#### ៩.៤.២-ការងារគណបក្សនយោបាយ

គិតមកដល់បច្ចុប្បន្នគណបក្សនយោបាយមានចំនួនសរុប ៤៦គណបក្ស ក្នុងនោះគណបក្សដែលបានចុះបញ្ជីចំនួន៤៥គណបក្ស និងគណបក្សដែលបានបង្កើតចំនួន ០១គណបក្ស ។ ដោយឡែកក្នុង ខែមិថុនា ឆ្នាំ២០២០

ក្រសួងមហាផ្ទៃបានសម្រេចលុបឈ្មោះចេញពីបញ្ជីគណបក្សបង្កើតចំនួន ០១ គឺគណបក្សដើម្បីយើងទាំងអស់គ្នា និងបានបញ្ចូលទិន្នន័យ ស្កេនសំណុំឯកសារពាក់ព័ន្ធរបស់គណបក្សនយោបាយចំនួន០២គឺ **គណបក្សខ្មែរស្រលាញ់ជាតិ និងគណបក្សកម្លាំងប្រជាធិបតេយ្យ**។ ទន្ទឹមនេះបានរៀបចំសេចក្តីព្រាងប្រកាសអន្តរ ក្រសួង រវាងក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកំណត់បង់អាករសម្រាប់ការចុះបញ្ជីគណបក្សនយោបាយដើម្បីស្នើសុំអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងផ្តល់យោបល់។

## II-បញ្ហាប្រឈម និងសំណូមពរ

ទន្ទឹមនឹងការសម្រេចលទ្ធផលដូចខាងលើ ក្នុងការបំពេញការកិច្ចកន្លងមក អគ្គនាយកដ្ឋានរដ្ឋបាលបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

-មិនទាន់បានដាក់ចេញគំរូពាក្យស្នើសុំ និងគំរូអាជ្ញាប័ណ្ណស្តង់ដារួមសម្រាប់ការផ្តល់សេវារដ្ឋបាល នៅអង្គភាពច្រកចេញចូលតែមួយ

-ទិន្នន័យផ្ទុកក្នុងប្រព័ន្ធ MIS កាន់តែច្រើនទៅៗធ្វើឱ្យប្រព័ន្ធ MIS ដំណើរការយឺតពិបាកក្នុងការផលិតរបាយការណ៍ចេញ

-ការផ្គត់ផ្គង់សម្ភារការិយាល័យដូចជាក្រដាសទឹកថ្នាំម៉ាស៊ីនថតចម្លងដើម្បីឆ្លើយតបសំណូមពរការងារមិនទាន់បានគ្រប់គ្រាន់ហើយការបើកសម្ភារៈពុំសូវមានគុណភាព

-ការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មសម្រាប់មន្ត្រីចុះបំពេញការងារនៅតាមខេត្ត មន្ត្រីរាជការត្រូវចំណាយថវិកាផ្ទាល់ខ្លួនជាមុនហើយបន្ទាប់ពីបញ្ចប់បេសកកម្មការបើកផ្តល់មានភាពយឺតយ៉ាវ

-មន្ត្រីមិនទាន់មានជំនាញគ្រប់គ្រាន់ ក្នុងការសសេរព័ត៌មាន និងគ្រប់គ្រងព័ត៌មានវិទ្យា ទាមទារត្រូវការបណ្តុះបណ្តាល

ដើម្បីជំរុញការអនុវត្តការងារឱ្យមានប្រសិទ្ធភាព ក៏ដូចជាការលើកទឹកចិត្តមន្ត្រី ក្នុងការបំពេញការងារ **អគ្គនាយកដ្ឋានរដ្ឋបាល** សំណូមពរដូចខាងក្រោម៖

-ផ្គត់ផ្គង់សម្ភារការិយាល័យឱ្យបានសមស្រប និងទាន់ពេលវេលាដើម្បីធានាឆ្លើយតបសំណូមពរការងារ

-ផ្តល់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មឱ្យបានលឿនជាងមុនបន្តិចបន្ទាប់ពីចុះបំពេញបេសកកម្ម។

## III-ទិសដៅការងារបន្ត

ដើម្បីជំរុញការអនុវត្តការងារឱ្យបានល្អប្រសើរ និងតាមផែនការដែលបានគ្រោងទុក អគ្គនាយកដ្ឋានរដ្ឋបាលបានដាក់ចេញនូវទិសដៅការងារបន្តសម្រាប់ខែកក្កដា ឆ្នាំ២០២០ដូចខាងក្រោម៖

### ១-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត

#### ១.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុងដែលកំពុងរៀបចំ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខ័ណ្ឌមន្ត្រពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងច្រកទ្វារព្រំដែននៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបចោលភូមិ និងការកែសម្រួលព្រំប្រទល់រដ្ឋបាល ថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី នីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
-សេចក្តីព្រាងសេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
-សេចក្តីព្រាងសេចក្តីណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់
-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការដាក់ឱ្យប្រើប្រាស់ទម្រង់ដីកានានាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
-សេចក្តីព្រាងសេចក្តីជូនដំណឹងស្តីពីការគ្រប់គ្រងមន្ត្រីរាជការនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌបន្ទាប់ពីការធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មី
-សេចក្តីព្រាងគំរូកិច្ចសន្យា ស្តីពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលក្រុង ស្រុក
-សេចក្តីព្រាងសៀវភៅណែនាំស្តីពីកម្មវិធីពានរង្វាន់សម្រាប់ការអនុវត្តសេវាសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
-សេចក្តីព្រាងសៀវភៅណែនាំស្តីពី"កិច្ចការរដ្ឋបាល"សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា(ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ។

**១.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ**

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ
-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ
-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល
-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
-សេចក្តីព្រាងកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤២ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
-សេចក្តីព្រាងកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤៣ ប្រ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
-សេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួង ស្តីពីនីតិវិធី នៃការចុះបញ្ជីសិប្បកម្មដែលមានដើមទុនសមមូលលើសពី៨០លានរៀលដល់២០០លានរៀល និងគ្មានហានិភ័យ
-សេចក្តីព្រាង សេចក្តីណែនាំអន្តរក្រសួង ស្តីពីបែបបទ និងនីតិវិធីសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងវិស័យសាធារណការ និងដឹកជញ្ជូន
-សេចក្តីព្រាង សេចក្តីណែនាំអន្តរក្រសួង ស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យឧស្សាហកម្ម និងសិប្បកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០២០-២០៣០។

**២-ការងារបុគ្គលិក**

**២.១-ការងារក្របខ័ណ្ឌ**

-បន្តរៀបចំបែបបទសុំដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ និងតាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០២០

-បន្តរៀបចំបែបបទសុំដំឡើងឋានន្តរស័ក្តិ ជូនមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទស្នើសុំផ្ទេរក្របខ័ណ្ឌពីមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃទៅក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗ និងពីក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗមកក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ដើម្បីទៅបំពេញការងារក្នុងមុខតំណែងថ្មីនិងអនុញ្ញាតឲ្យមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌដើមវិញ

-បន្តរៀបចំបែបបទដើម្បីតាំងស៊ប់ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទ ដើម្បីសុំពិនិត្យនីត្យានុកូលភាពលើប្រកាសតែងតាំង និងប្រគល់ភារកិច្ច ដើម្បីស្នើសុំផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទផ្តល់ទិដ្ឋាការលើសលាកបត្រជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ។

**២.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល**

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីរាជការដែលទទួលមរណភាពនិងមន្ត្រីរាជការដែលសុំលាឈប់ពីការងារ

-បន្តរៀបចំផ្តល់ប័ណ្ណសម្គាល់ខ្លួនជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតអនុញ្ញាត ឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញ បន្ទាប់ពីសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីដែលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយហួសកាលកំណត់

-បន្តរៀបចំសំណុំលិខិតអនុញ្ញាតឈប់សម្រាកលំហែមាតុភាព

-បន្តរៀបចំសំណុំបែបបទផ្ទេរកូនកំព្រា និងសុំប្រាក់ធានារ៉ាប់រងសង្គម

-បន្តពិនិត្យផ្ទៀងផ្ទាត់សលាកបត្រមន្ត្រីរាជការស៊ីវិលនិងមន្ត្រីពន្ធនាគារដែលដល់អាយុត្រូវចូលនិវត្តន៍ឆ្នាំ២០២០

-បន្តពិនិត្យផ្ទៀងផ្ទាត់ការស្នើសុំគ្រឿងឥស្សរិយយសមេដាយការងារ និងប័ណ្ណសរសើ ជូនមន្ត្រីរាជការស៊ីវិល។

**២.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ**

-បន្តរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាពសម្រាប់ខែបន្ទាប់របស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួង

-បន្តរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាពទីប្រឹក្សា ជំនួយការក្រសួងមហាផ្ទៃ

-បន្តរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាពទីប្រឹក្សា ជំនួយការ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បន្តធ្វើការតែងតាំងទីប្រឹក្សា ជំនួយការ

-បន្តរៀបចំស្នើសុំប្រាក់បៀវត្សទីប្រឹក្សា ជំនួយការ

-បន្តរៀបចំការងារពិពណ៌នាមុខតំណែងមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-បន្តរៀបចំសំណើសុំគោលការណ៍ពិនិត្យសម្រេច លើការតែងតាំង ផ្ទេរ និងប្រគល់ភារកិច្ចមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ

-បន្តរៀបចំការផ្លាស់ប្តូរកន្លែងធ្វើការងាររបស់មន្ត្រីរាជការស៊ីវិល

-រៀបចំដាក់ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិរយៈពេល០៣ខែនិងដាក់ទណ្ឌកម្មខាងវិន័យសម្រាប់មន្ត្រីពន្ធនាគារ

-បន្តរៀបចំការផ្អាកការងារដោយផ្អាកបៀវត្ស។

**២.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធ ក្នុងការចុះពង្រឹងរបៀបរបបការងារ និងការគ្រប់គ្រងមន្ត្រីរាជការ នៅតាមសាលារាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

-ពិនិត្យ និងសិក្សាលើសំណើសុំកែសម្រួលរចនាសម្ព័ន្ធទីចាត់ការ អង្គភាព និងការិយាល័យនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តពិនិត្យ និងលើកយោបល់ ដើម្បីស្នើសុំការសម្រេចលើការតែងតាំងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវដល់អាណត្តិ ០៤ឆ្នាំ(និង០៨ឆ្នាំ)របស់ខ្លួន

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បន្តសហការ និងសម្របសម្រួលជាមួយនឹងអង្គភាពប្រឆាំងអំពើពុករលួយលើការងារប្រកាសទ្រព្យសម្បត្តិនិងបំណុលសម្រាប់ឆ្នាំ២០២០។

**២.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តយកចិត្តទុកដាក់ពិនិត្យលើកយោបល់ទាក់ទងការផ្លាស់ប្តូរ និងទទួលស្គាល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានទាន់ពេលវេលា

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

**២.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

-ធ្វើបច្ចុប្បន្នភាពដោយកែតម្រូវព័ត៌មានប្រវត្តិរូបរបស់មន្ត្រីរាជការក្នុងប្រព័ន្ធទិន្នន័យសម្រាប់ខេត្តបន្ទាយមានជ័យ

-បន្តសហការជាមួយក្រុមហ៊ុនក្នុងការរៀបចំប្រព័ន្ធឲ្យមានភាពល្អប្រសើរជាងមុន

-បន្តសហការជាមួយមន្ត្រីបង្គោល នៃរដ្ឋបាលរាជធានី ខេត្ត ដើម្បីប្រមូលប្រវត្តិរូបមន្ត្រីកម្មសិក្សាក្របខ័ណ្ឌថ្មី ឆ្នាំ ២០១៩ និងមន្ត្រីដែលទើបផ្ទេរចូលថ្មី រួមទាំងឯកសារមន្ត្រីរាជការដែលមានការប្រែប្រួលស្ថានភាពជាបន្តបន្ទាប់

-បន្តសហការណ៍ជាមួយការិយាល័យជំនាញពាក់ព័ន្ធដើម្បីធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការដូចជា៖ការផ្លាស់ប្តូរកន្លែងធ្វើការ ការតែងតាំង ការប្រែប្រួលថ្នាក់ ឋានន្តរស័ក្តិ ការលុបឈ្មោះ ការចូលនិវត្តន៍...។ល។

**៣-ការងារអភិវឌ្ឍន៍សមត្ថភាព**

**៣.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស**

-រៀបចំវគ្គភាពជាអ្នកដឹកនាំសម្រាប់ថ្នាក់ដឹកនាំនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

-រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការអប់រំភាពជាអ្នកដឹកនាំដោយសហការជាមួយអង្គការ Watershed

-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់រាជធានី ខេត្ត ស្របតាមផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ ស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តរៀបចំឯកសារបណ្តុះបណ្តាលកិច្ចការរដ្ឋបាល ការងារបុគ្គលិក និងការងារហិរញ្ញវត្ថុសម្រាប់ក្រុមគោលដៅមន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅអំឡុងត្រីមាសទី៣ ឆ្នាំ២០២០

-បន្តរៀបចំកិច្ចការចាំបាច់នានាសម្រាប់ដាក់ឲ្យដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាន(NASLA )

-បន្តសិក្សាស្រាវជ្រាវ និងចងក្រងឯកសារអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា និងបរទេស

-កំពុងរៀបចំប្រមូលទិន្នន័យរបាយការណ៍ស្តីពីការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួង-មហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ត្រីមាសទី១ឆ្នាំ២០២០

-បន្តចងក្រងទិន្នន័យអភិវឌ្ឍសមត្ថភាព។

**៣.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន**

-បន្តរៀបចំបែបបទដើម្បីបញ្ជូនមន្ត្រីទៅចូលរួមសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនៅក្រៅប្រទេស

-បន្តសហការជាមួយដៃគូ ដើម្បីស្វែងរកការគាំទ្រ និងកិច្ចសហការសម្រាប់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទ ដើម្បីស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការតាមការស្នើសុំពីមន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**៣.៣-ការងារផ្សព្វផ្សាយ និងព័ត៌មាន**

-បន្តធ្វើបច្ចុប្បន្នភាពនិងបញ្ចូលអត្ថបទក្នុងគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល

-បន្តស្រាវជ្រាវ និងសរសេរអត្ថបទដើម្បីបញ្ចូលទៅក្នុងព្រឹត្តិបត្រ «វិមជ្ឈការ និងវិសហមជ្ឈការ» ក្រសួងមហាផ្ទៃលេខ ០៤។

## ៤-ការគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ

### ៤.១-ការគាំទ្របច្ចេកទេស និងអន្តរាគមន៍

ដើម្បីគាំទ្រដល់ការបំពេញតួនាទីភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច និងបន្តអនុវត្តលើកិច្ចការមួយចំនួនដូចខាងក្រោម៖

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តរតនគិរី ស្នើសុំពិនិត្យសម្រេចលើការកំណត់និមិត្តសញ្ញារបស់រដ្ឋបាលខេត្តរតនគិរី សម្រាប់ប្រើប្រាស់ជាផ្លូវការ។

-បន្តពិនិត្យ និងលើកយោបល់ ករណីតំណាងប្រជាពលរដ្ឋ ៧៤៣គ្រួសារ ស្នើសុំជួយជំរុញ និងពន្លឿនការដោះស្រាយជម្លោះដីធ្លីរវាងប្រជាពលរដ្ឋចំនួន ៧៤៣គ្រួសារ ជាមួយក្រុមហ៊ុន កោះកុងស៊ូហ្គើ និងកោះកុង ផ្លេនថេសិនអ៊ីនដាស់ស្ទ្រី ខមផេនី លីមិតធីត របស់លោកឧកញ៉ា លី យ៉ុងផាត់ នៅក្នុងទឹកដីស្រុកបូទុមសាគរ ស្រុកថ្មបាំង និងស្រុកស្រែអំបិល។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ អ៊ឹត ថាន និងអ៊ិត សាមឿន ស្នើសុំអន្តរាគមន៍ទៅលើឈ្មោះនូវ ស្រស់, ង៉ាន់ ហ្វារីតា, សូ ឈី, ហែម ហ៊ន, យន់ ប៊ុនលាង, ប៉ាត ស៊ុយ, វ៉ា ម៉េង និងបក្ខពួក ដែលបានរំលោភយកដីរបស់ប្រជាពលរដ្ឋ ១៤២គ្រួសារ ដោយរំលោភលើលិខិតលេខ ១៤០៦ សជណ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តស្ទឹងត្រែងធ្វើសេចក្តីរាយការណ៍អំពីការចុះទប់ស្កាត់ការកាប់ទន្ទ្រានដីព្រៃឈើយកធ្វើជាកម្មសិទ្ធិត្រង់ចំណុចដៃអូរសេរ ភូមិបានបុង ឃុំក្អួក ស្រុកសេសាន ខេត្តស្ទឹងត្រែង។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះម៉ែន មាន,ពេជ្យ សុពេញ, អ៊ុំ សម្បត្តិ,ហង្ស យឿន និងឈ្មោះផុន ផល្លាតំណាងប្រជាពលរដ្ឋ ៣១គ្រួសារ ស្នើសុំប្តឹងឈ្មោះ យ៉ែម សារឿន ពីបទក្លែងបន្លំឯកសារដោយបន្លំខ្លួនធ្វើជាតំណាងប្រជាពលរដ្ឋសហគមន៍បឹងកញ្ច្រាំចំនួន ៣១គ្រួសារ ដើម្បីទាមទារដីទំហំ៨,៦ហិកតា ស្ថិតនៅភូមិព្រែកកក្តី ឃុំព្រែកតាទែន ស្រុកពញាឮមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។

-បន្តពិនិត្យនិងលើកយោបល់ ករណីរដ្ឋបាលខេត្តកំពង់ចាមធ្វើសេចក្តីរាយការណ៍អំពីការរកឃើញនាវាចំបាំង និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលបានលិចក្នុងទន្លេ ស្ថិតនៅភូមិវាល ឃុំមានជ័យ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ ឆាយ រិនិតា ស្នើសុំបដិសេធលិខិតលេខ ២១២/២០ របក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ។

-បន្តពិនិត្យនិងលើកយោបល់ ករណីរដ្ឋបាលខេត្តកំពង់ឆ្នាំងធ្វើសេចក្តីរាយការណ៍អំពីករណីជនល្មើសលួចឈូសឆាយ កាប់ព្រៃ បោះបង្គោល និងសង់ខ្ទមចូលដែនជម្រកសត្វព្រៃឱរ៉ាល់ ស្ថិតក្នុងឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ ផាន់ សាមន្តា ស្នើសុំជួយរកដំណោះស្រាយដីមួយកន្លែងទំហំ ១៦០.០០០ម៉ែត្រការ៉េ ស្ថិតនៅភូមិគីឡូម៉ែត្រលេខ ៤ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តស្ទឹងត្រែង ស្នើសុំកែសម្រួលទម្រង់រាងនៃនិមិត្តសញ្ញាខេត្តស្ទឹងត្រែង។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តកំពង់ឆ្នាំងធ្វើសេចក្តីរាយការណ៍អំពីការរៀបចំអនុវត្តវិធានការរដ្ឋបាលលើការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុដទៃទៀតតាមច្បាប់អស្សាមិករណ៍សម្រាប់គម្រោងស្តារឡើងវិញកំណាត់ផ្លូវជាតិលេខ ៥។

-បន្តពិនិត្យ និងលើកយោបល់ ករណីស្នងការដ្ឋាននគរបាលខេត្តកំពង់ចាមធ្វើសេចក្តីរាយការណ៍ឆ្លើយតបនឹងបណ្តឹងរបស់ឈ្មោះ សែម បូ៉ា ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ មុខរបរជាអគ្គនាយកទូរទស្សន៍អនឡាញ ធី អ៊ិន អឹម (TNM TV online) មានទីលំនៅផ្ទះលេខ ១១A សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះហង់ យ៉យ,ហៃ គឹមហឿន,ឃិន ប៉ោលី និងឈ្មោះអ៊ូ ហ៊្សារ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលរាជធានីភ្នំពេញឱ្យជួយដោះស្រាយវិវាទដីធ្លីទំហំ ១.០៣៧.៥៣៩ម៉ែត្រការ៉េរបស់ប្រជាពលរដ្ឋចំនួន ១០៥គ្រួសារ ស្ថិតនៅភូមិចុងកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះគួយ សារឿន,គាត់ ម៉ីន,ត្វាន ញ៉ាន,វ៉ៃ ក្រេង,ចាម ថៃក តំណាងប្រជាពលរដ្ឋចំនួន ៥៣គ្រួសារ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តមណ្ឌលគិរី ជួយបែងចែកដីធ្លីកម្មសិទ្ធិស្របច្បាប់ដល់ពួកគាត់ ស្ថិតនៅភូមិក្លុងឡែ ឃុំសុខសាន្ត ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដើម្បីបានប្រើប្រាស់ និងអាស្រ័យផល។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ ជួប សម្បត្តិ, រស់ ប្រុស, យ៉េន ស៊ីនឿន និងឈ្មោះ ជួន រី តំណាងប្រជាពលរដ្ឋចំនួន ១៥គ្រួសារ ស្នើសុំអន្តរាគមន៍ដោះស្រាយវិវាទដីធ្លីជាមួយក្រុមហ៊ុន អាន សុភី, ក្រុមហ៊ុនហ្គោល ដេន, ក្រុមហ៊ុន នុភាព សុភី និងក្រុមហ៊ុន ខេមបូឌា ហ្វាម៉ វ និងសុំចេញប័ណ្ណកម្មសិទ្ធិ ស្ថិតនៅតំបន់អូរតាម៉ាន់ តំបន់ចង្វាឆ្លក និងតំបន់អូរតាចក់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ ចេង សុណាត, ឈួក សារ៉ុម, ម៉េង កៅ, លី គីមហួ, លី យ៉ាវ និងឈ្មោះ លី សម្បត្តិ ស្នើសុំអន្តរាគមន៍ដោះស្រាយលើវិវាទដីចិញ្ចឹមត្រី ស្ថិតនៅភូមិដូង សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ ជាមួយក្រុមហ៊ុន ឡាយធី។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តមណ្ឌលគិរីធ្វើសេចក្តីរាយការណ៍អំពីការដាំដុះដំណាំ និងអាស្រ័យផលលើដីដែលបានកាប់រានក្នុងដែនជម្រកសត្វព្រៃ ស្ថិតក្នុងភូមិសាស្ត្រស្រុកកែវសីមា និងស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ ពុធ ម៉េងគួង, ពុត គង់ និងឈ្មោះ កាង ឈុនឡុន ស្នើសុំជួយរកយុត្តិធម៌ និងដោះស្រាយករណីឈ្មោះ ហុក ម៉ាក់ឌី មិនឱ្យធ្វើអាជីវកម្មលើទីតាំងដីដែលមានអាជ្ញាប័ណ្ណរួចហើយ ស្ថិតនៅភូមិសំពៅ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ ឥន្ទ គា,ឡុក ស្រីពៅ,ខាត់ សកំដា,តាំង សៀន,ស៊ុំ សុលី, អៀម នាង,អ៊ុច ប៊ុណ្ណា,ហាក់ ហេង,ថាវ សុគន្ធ,ប៉ុក គន្ធា,សែត ឌុន និងឈ្មោះជួង សុខា ស្នើសុំអន្តរាគមន៍មករដ្ឋបាលខេត្តតាកែវបង្កើតគណៈកម្មការចម្រុះថ្នាក់ខេត្ត ចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំ និងអង្កេតដីជាក់ស្តែងទំហំ ៣.២៣៣ម៉ែត្រការ៉េ ស្ថិតនៅភូមិ២ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ។

-បន្តពិនិត្យ និងលើកយោបល់ ករណីមេធាវីឈ្មោះ ដារ៉ា សុបញ្ញា ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលរាជធានីភ្នំពេញ ជួយដោះស្រាយបញ្ហាដីធ្លីទំហំ ១៩២.៥៧៣,៧ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិខ្នង សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

-បន្តពិនិត្យ និងលើកយោបល់ ករណីអង្គការ Wildlife Alliance ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តពោធិ៍សាត់បញ្ឈប់ការលូកដៃក្នុងការងារអនុវត្តច្បាប់របស់មន្ត្រីឧទ្យានុរក្ស និងរបស់ស្ថាប័នតុលាការ។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ ច័ន្ទ រិទ្ធី, ណុប រស្មី, ស្រី សន, យុន ណាន់, សៅ ផល្លា, ណុប កក្កដា, សំ ស្រីអូន, ប៉ា ណារ័ត្ន និងឈ្មោះ គង់ ស្រីណា ស្នើសុំអន្តរាគមន៍រុះរើកញ្ចុះថ្ម និងតូបទូរស័ព្ទរបស់ឈ្មោះ រិទ្ធ រ៉ារី ដែលស្ថិតនៅក្នុងចំណតបេនឡានទំហំ ៧៦ម៉ែត្រ x ១៩ម៉ែត្រ, ស្នើសុំស្រាវជ្រាវលិខិតផ្ទេរសិទ្ធិចំនួន ១៤ គ្រួសារ ដែលទិញពីក្រុមហ៊ុន 7NG និងបញ្ឈប់ការលក់ដូរ និងជួលទីតាំងចំណតឡានក្រុងទាំងមូលនៅមុខផ្ទះ ១៤A1 ដល់២៩A1 ស្ថិតនៅបុរីសន្តិភាព២ ផ្លូវសន្តិភាព ភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ សេង ចាយ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុ ជួយបង្កើតគណៈកម្មការចម្រុះថ្នាក់ខេត្ត និងចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំ អង្កេត និងសុំកាត់ឆ្វៀលដីទំហំ ០៩ហិកតា ៧៥អា ចេញពីតំបន់គម្របព្រៃឈើ ដើម្បីចុះបញ្ជីក្បាលដី កសាងប័ណ្ណកម្មសិទ្ធិ និងផ្លាស់ប្តូរប័ណ្ណកម្មសិទ្ធិថ្មី ស្ថិតនៅភូមិស្រែចាមលើ ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ ពេជ្រ សូរិយា, ហ៊ីង សុវណ្ណ, ផេង ប៊ុនធឿន, សំ ប៉ាក់, សៀង ផាត ,មាស រតនា,ខឹម សុផល, អ៊ឹម ម៉ៅ,ជីវ ជីន និងឈ្មោះ ជូ សៀម ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុ ជួយបង្កើតគណៈកម្មការចម្រុះថ្នាក់ខេត្ត និងចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំ អង្កេត និងសុំកាត់ឆ្វៀលដីទំហំ ៨០ហិកតា ចេញពីតំបន់គម្របព្រៃឈើ ដើម្បីចុះបញ្ជីក្បាលដី កសាងប័ណ្ណកម្មសិទ្ធិ និងផ្លាស់ប្តូរប័ណ្ណកម្មសិទ្ធិថ្មី ស្ថិតនៅភូមិអូរគគីរ ឃុំបិតត្រាំង,ភូមិចំការកៅស៊ូ ឃុំជើងគោ និងភូមិអូរត្រជាក់ចិត្ត ឃុំសំរុង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ ដាន គី, ស៊ីវ អេង, សេង ចាយ និងឈ្មោះ អៀវ ហ៊ួយ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុ ជួយបង្កើតគណៈកម្មការចម្រុះថ្នាក់ខេត្ត និងចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំង វាស់វែង កំណត់ព្រំ អង្កេត និងសុំកាត់ឆ្វៀលដីទំហំ ២៥០ហិកតា ចេញពីតំបន់គម្របព្រៃឈើ ដើម្បីចុះបញ្ជីក្បាលដី កសាងប័ណ្ណកម្មសិទ្ធិ និងផ្លាស់ប្តូរប័ណ្ណកម្មសិទ្ធិថ្មី ស្ថិតនៅភូមិ០៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

-បន្តរៀបចំ កែសម្រួលនូវប្រព័ន្ធរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរៀបចំប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត។

-បន្តរៀបចំបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

-ត្រៀមរៀបចំចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញក្នុងការិយបរិច្ឆេទឆ្នាំ២០២០។

**៤.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

អគ្គនាយកដ្ឋានរដ្ឋបាល បន្តពិនិត្យ និងលើកយោបល់ ជូនថ្នាក់ដឹកនាំក្រសួងពាក់ព័ន្ធនឹងការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការបង្កើតភូមិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

-**រដ្ឋបាលខេត្តបន្ទាយមានជ័យ** ករណីស្នើសុំបង្កើតភូមិថ្មីចំនួន ០២ ស្ថិតក្នុងឃុំណាំតៅ ស្រុកភ្នំស្រុក និងភូមិចំនួន ០៥ ស្ថិតក្នុងឃុំតាគង់ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

-**រដ្ឋបាលខេត្តតាកែវ** ករណីរដ្ឋបាលឃុំកំពង់រាប ស្នើសុំបំបែកភូមិ ចំនួន ០៣ ស្ថិតក្នុងឃុំកំពង់រាប ចំនួន ០២ភូមិ និងឃុំព្រៃល្វា ចំនួន០១ភូមិ នៃស្រុកព្រៃកប្បាស ខេត្តតាកែវ។

-**រដ្ឋបាលខេត្តព្រៃវែង** ករណីស្នើសុំបំបែកភូមិចំនួន ០៤ភូមិ ស្ថិតនៅក្នុងឃុំកំពង់ពពិល ចំនួន ០១ភូមិ និងឃុំកញ្ចំ ចំនួន ០៣ភូមិ នៃស្រុកពារាំង ខេត្តព្រៃវែង។

-**រដ្ឋបាលខេត្តសៀមរាប ព្រះវិហារ ឧត្តរមានជ័យ និងខេត្តបាត់ដំបង** ករណីស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងខេត្តសៀមរាបជាមួយខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង។

-**រដ្ឋបាលខេត្តកំពង់ស្ពឺ** ករណីស្នើសុំបង្កើតភូមិថ្មីចំនួន ០១ ស្ថិតនៅឃុំវល្លិសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

**៤.៣-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

-បន្តតាមដាន ត្រួតពិនិត្យអំពីការអនុវត្តលិខិតលេខ ១៩៧៣ស.ជ.ណ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការពង្រឹងការគ្រប់គ្រង ការស្នើសុំគ្រឿងឥស្សរិយយសស្ថាបនាជាតិ និងគោរមងារជាឧកញ៉ាជូនសប្បុរសជនដែលមានស្នាដៃ និងគុណបំណាច់ក្នុងការជួយកសាងជាតិក្នុងព្រះរាជាណាចក្រកម្ពុជា។

-បន្តពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួង ករណីសំណើសុំគ្រឿងឥស្សរិយយសរបស់រដ្ឋបាលខេត្តកំពង់ចាម និងខេត្តព្រៃវែង។

**៤.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា**

**៤.៤.១-កម្មវិធីគាំទ្រដោយអង្គការ UNICEF**

-គ្រោងរៀបចំសិក្ខាសាលា ស្តីពីការរៀបចំបញ្ចូលគម្រោងសេវាសង្គមទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ជួយគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងអ្នកពាក់ព័ន្ធឲ្យមានសមត្ថភាពក្នុងការរៀបចំបញ្ចូលគម្រោង ឬសកម្មភាពសេវាសង្គមទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ ទៅដល់រដ្ឋបាលរាជធានី ខេត្ត ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ។

- រៀបចំកិច្ចប្រជុំប្រចាំត្រីមាសស្តីពីការគាំទ្ររបស់រដ្ឋបាលរាជធានី ខេត្តដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់លើការរៀបចំ និងអនុវត្តគម្រោងក្រុង ស្រុក ឃុំ សង្កាត់

-បន្តរៀបចំសេចក្តីព្រាងសៀវភៅណែនាំ ស្តីពីកម្មវិធីពានរង្វាន់សម្រាប់ការអនុវត្តសេវាសង្គម នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

-រៀបចំលិខិតស្នើសុំគោលការណ៍បន្តកិច្ចសន្យាជាមួយទីប្រឹក្សាថ្នាក់ជាតិ លោកស្រី **សម្បត្តិ រតនា** ដើម្បីបញ្ចប់ការរៀបចំប្រព័ន្ធទិន្នន័យ។

-បន្តរៀបចំប្រព័ន្ធទិន្នន័យអនឡាញ៍ (Data Base of SNAs) របស់រដ្ឋបាលរាជធានី ខេត្ត។

-បន្តបច្ចុប្បន្នភាពស្ថានភាព និងទីតាំងអគាររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ប្រចាំត្រីមាសទី១ ឆ្នាំ២០២០។

**៤.៤.២-គម្រោងសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP**

-បន្តតាមដាន និងសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពាក់ព័ន្ធនឹងសំណើសុំថវិកាបន្ថែម ដើម្បីរក្សាការសាងសង់អគាររដ្ឋបាល អគារសាលប្រជុំ និងអគាររដ្ឋបាលឃុំ សង្កាត់ តាមចំនួនដែលបានគ្រោងទុកក្នុងផែនការអនុវត្តរបស់គម្រោង។

-បន្តចុះពិនិត្យ តាមដាន និងជំរុញដំណើរការសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ សម្រាប់ដំណាក់កាលទី១ ទី២ និងទី៣ ឱ្យបានសម្រេចតាមផែនការរបស់គម្រោង។

-រៀបចំឯកសារវាយតម្លៃទីប្រឹក្សាបច្ចេកទេសគម្រោងចំនួន០៦រូប ដើម្បីស្នើសុំការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៤.៥-ការងាររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់**

-បន្តធ្វើបច្ចុប្បន្នភាពដំណើរការកសាងកម្មវិធីវិនិយោគក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០២០-២០២២

-បន្តជម្រុញការរៀបចំផែនការអភិវឌ្ឍប្រាំឆ្នាំ២០២០-២០២៤របស់រដ្ឋបាលក្រុង ស្រុក

-បន្តគាំទ្រ និងតាមដានដំណើរការសិក្សារៀបចំគម្រោងក្រុង ស្រុក ឃុំ សង្កាត់ និងតាមដានវាយតម្លៃគម្រោង

-បន្តគាំទ្រ និងតាមដានដំណើរការលទ្ធកម្ម និងគ្រប់គ្រងកិច្ចសន្យារបស់រដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់

-បន្តគាំទ្រ និងតាមដានដំណើរការសិក្សា រៀបចំគម្រោងក្រុង ស្រុក ឃុំ សង្កាត់ កិច្ចសហប្រតិបត្តិការថែទាំគម្រោង ព្រមទាំងតាមដាន និងវាយតម្លៃគម្រោង។

-ពង្រឹង និងពន្លឿនការចាត់ចែង ដោះស្រាយពាក្យបណ្តឹងនានាដែលពាក់ព័ន្ធនឹងក្រុង ស្រុក ឃុំ សង្កាត់

-បន្តរៀបចំអនុវត្តការតាមដានការអនុវត្តតួនាទីភារកិច្ច និងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់

-ចុះតាមដានការអនុវត្តថវិកាក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០១៩។

**៤.៦-ការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

-រៀបចំកិច្ចប្រជុំពិនិត្យលើឯកសារទស្សនទាន និងបញ្ជីសំណួរ សម្រាប់ចុះសិក្សាការរៀបចំការិយាល័យច្រកចេញចូលតែមួយ ការកែសម្រួលតួនាទី ភារកិច្ច និងនីតិវិធីនៃការផ្តល់សេវារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

-តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់ការផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-រៀបចំកិច្ចប្រជុំអន្តរក្រសួង រវាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន និងលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីពិនិត្យ និងផ្តល់យោបល់លើការរៀបចំសេចក្តីព្រាងគំរូកិច្ចសន្យា ស្តីពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលក្រុង ស្រុក

-បន្តសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធផ្សេងៗ និងលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងដំណើរការរៀបចំផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

-ផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-ដាក់ឱ្យដំណើរការសាកល្បងកម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-គាំទ្រដំណើរការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋខណ្ឌទាំង៤ រួមមាន៖ ខណ្ឌជ្រោយចង្វារ ខណ្ឌព្រែកព្នៅ ខណ្ឌមានជ័យ និងខណ្ឌដូនពេញ នៃរាជធានីភ្នំពេញ។

-រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីសម្រុះសម្រួលដោះស្រាយបណ្តឹង និងកត់ត្រាបណ្តឹងនៅតុពិសេសដល់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌចំនួន ៨៨គោលដៅ។

**៥-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

ដើម្បីលើកកម្ពស់កិច្ចសហការជាមួយក្រសួង ស្ថាប័ននានា អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យ និងលើកយោបល់លើករណីដូចខាងក្រោម៖

-ត្រៀមសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សា និងរៀបចំទិន្នន័យដើមគ្រានៃការផ្តល់សេវាក្នុងវិស័យសុខាភិបាលនៅមូលដ្ឋាន។

-បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកិច្ចប្រជុំពិភាក្សាអំពីគម្រោងកម្មវិធីការពារពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍ និងសហគមន៍ពីហានិភ័យឆ្លងជំងឺកូវីដ១៩ទ្រង់ទ្រាយធំ និងការផ្តល់សេវាចាំបាច់នានានៅមូលដ្ឋាន ក្រោមអធិបតីភាពសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**៦-ការងារតាមវិស័យផ្សេងៗ**

**៦.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងប័ណ្ណព្រំដែន**

**ក.ការងារច្រកទ្វារព្រំដែន**

-បន្តតាមដានករណីភាគីវៀតណាមបោះតង់ប៉ុស្តិ៍ដោយលើកស្លាកទប់ស្កាត់ជំងឺកូវីត-១៩ចំនួន២៥៦ ទីតាំងនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម។

-បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងដើម្បីសិក្សា និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់-ទន្លេហ៊្វូវ និងព្រែកជ្រៃធំ-ព្រែកបិញយី នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម។

-បន្តសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ករណី៖

• សិក្សានិងលើកយោបល់លើកិច្ចព្រមព្រៀងសាងសង់ស្ពានថ្មីនៅច្រកទ្វារព្រំដែនអន្តរជាតិព្រំ (ប៉ៃលិន)-បានផាកកាដ(ច័ន្ទបុរី) ដើម្បីមានមូលដ្ឋានស្នើសុំគោលការណ៍សម្រេចពីប្រមុខរាជរដ្ឋាភិបាល។

• ភាគីវៀតណាមបោះតង់ និងប៉ុស្តិ៍យាមនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ដើម្បីមានមូលដ្ឋានលើកយោបល់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេចនិងឈានទៅធ្វើការតវ៉ាជាថ្មីឱ្យភាគីវៀតណាមរុះរើចេញនូវសំណង់ទាំងនោះចេញ និងរក្សាស្ថានភាពដដែល ស្របតាមកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលទាំងពីរ និងគោលការណ៍ច្បាប់អន្តរជាតិជាធរមាន។

-រដ្ឋបាលខេត្តកណ្តាល ករណីសកម្មភាពបូមខ្សាច់របស់ភាគីវៀតណាម នៅក្បែរតំបន់ព្រំដែនកម្ពុជា-វៀតណាម ស្ថិតនៅភូមិក្អមសំណាក្រោម ឃុំក្អមសំណា ស្រុកលើកដែក ខេត្តកណ្តាល។

-រដ្ឋបាលខេត្តកំពត ករណីស្នើសុំបង្កើតច្រកទ្វារព្រំដែនថ្មីចំនួន ០២ ស្ថិតក្នុងស្រុកបន្ទាយមាស ខេត្តកំពត។

**ខ.ការងារប័ណ្ណព្រំដែន**

-បន្តតាមដាន និងគាំទ្រដល់រដ្ឋបាលខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវអំពីដំណើរការផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋខ្មែរនៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ ប្រើប្រាស់ព្រមទាំងបន្តតាមដាន និងសិក្សាលទ្ធភាពក្នុងការផ្តល់សេវាប័ណ្ណព្រំដែននៅរដ្ឋបាលក្រុង ស្រុក និងច្រកទ្វារព្រំដែននៃបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ។

-បន្តតាមដាន និងសិក្សាលទ្ធភាពក្នុងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យប័ណ្ណព្រំដែនកម្ពុជា/ថៃឱ្យមានភាពប្រសើរឡើង និងប្រសិទ្ធភាពខ្ពស់។

**៦.២-ការងារចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី៧ ដែលភាគីថៃទទួលធ្វើជាម្ចាស់ផ្ទះក្នុងឆ្នាំ២០២០។

- បន្តសម្របសម្រួលលើការងាររៀបចំកិច្ចប្រជុំលើកទី២ របស់ក្រុមការងារចម្រុះ ស្តីពីច្រកទ្វារព្រំដែនគោក កម្ពុជា-វៀតណាម។

- បន្តសម្របសម្រួលលើការងាររៀបចំកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាមលើកទី១១។

**៦.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ**

អគ្គនាយកដ្ឋានរដ្ឋបាល បន្តពិនិត្យ និងលើកយោបល់ចំពោះសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម៖

-បន្តពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំ ករណីសំណើសុំផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍឆ្នាំ២០២០ ចំនួន ៩គម្រោង រួមមានៈ ខេត្តបាត់ដំបង(៤គម្រោង) ខេត្តកំពង់ចាម(៣គម្រោង) និងខេត្តស្ទឹងត្រែង(២គម្រោង) មានទឹកប្រាក់សរុបចំនួន ១២.៣០៥.០០០.០០០រៀល (ដប់ពីរប៊ីលានបីរយប្រាំលានរៀលគត់)។

-បន្តពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំ ករណីរដ្ឋបាលខេត្តកំពង់ស្ពឺស្នើសុំសាងសង់អគារសាលាឃុំ សង្កាត់ចំនួន៣ គឺសាលាសង្កាត់ស្វាយក្រវ៉ាន់ សាលាសង្កាត់កណ្តាលជុំ ក្នុងក្រុងច្បារមន និងសាលាឃុំក្រាំងដីវ៉ាយ ក្នុងស្រុកភ្នំស្រួច ដោយប្រើប្រាស់ថវិការបស់រដ្ឋបាលខេត្តឆ្នាំ២០២០ជំនួសវិញ ដោយក្នុងឆ្នាំ២០១៨ រដ្ឋបាលខេត្ត កំពង់ស្ពឺបានទទួលគម្រោងសាងសង់អគារសាលាឃុំ សង្កាត់ទាំង៣នេះ ពីគម្រោងសាងសង់អគាររដ្ឋបាលសាលា ស្រុក និងអគាររដ្ឋបាលសាលាឃុំ សង្កាត់ (DCFP) របស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ក្រោមក្របខណ្ឌ មូលនិធិទ្រទ្រង់ថវិកាឆ្នាំ២០១៦-២០១៩ ហើយមកដល់ឆ្នាំ២០២០នេះនៅមិនទាន់បានទទួលនៅឡើយ។

-បន្តលើកយោបល់សំណើរផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍ ឆ្នាំ២០២០ របស់រដ្ឋបាលរាជធានី ខេត្ត។

-បន្តពិនិត្យ និងលើកយោបល់សំណើសុំផ្តល់អនុលោមភាពនិងផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ (២០២០-២០២៤)របស់រដ្ឋបាលខេត្ត។

-បន្តពិនិត្យ និងលើកយោបល់ ករណីស្នើសុំគោលការណ៍ដោះដូរដីរបស់រដ្ឋបាលខេត្តស្ទឹងត្រែងទំហំ ៥៩,៤៤ហិកតា ស្ថិតនៅភូមិគីឡូ៨ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ជាមួយដីកាគីឯកជនចំនួន ២០០ឡូតិ៍ ដែល ក្នុងមួយឡូតិ៍ទំហំ ៥ម៉ែត្រ x ២០ម៉ែត្រ ស្ថិតនៅភូមិរាជានុកុល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

-បន្តពិនិត្យ និងលើកយោបល់ ករណីសំណើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនូវអគារ ០១ខ្នង ទំហំ ៨,២០ម៉ែត្រ x ២៩,៧០ម៉ែត្រ របស់រដ្ឋបាលស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

-បន្តពិនិត្យ និងលើកយោបល់ ករណីសំណើសុំផ្ទេរការចុះបញ្ជីដីផ្ទះមុខងារគ្រៀម ពីបញ្ជីសារពើភណ្ឌទ្រព្យ សម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តកែប ទៅចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងមុខងារសាធារណៈ។

-បន្តពិនិត្យ និងលើកយោបល់ ករណីសំណើសុំរុះរើ និងជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនូវ អគារផ្ទះភ្ញៀវចំនួន ០១ខ្នង និងអគារការិយាល័យចំនួន ០៤ របស់រដ្ឋបាលស្រុកជើងព្រៃ ខេត្តកំពង់ចាម។

-បន្តពិនិត្យ និងលើកយោបល់ ករណីសំណើសុំស្តាបនាសំណង់ទំនប់បង្ហៀរស្ទឹងមង្គលបុរី(ស្ទឹងម្នាល់កាល) ប្រសព្វនឹងស្ទឹងកំរៀងចំនួន ០១កន្លែង មានមុខកាត់ទទឹងស្ទឹង ២៤ម៉ែត្រ និងកម្ពស់ ១០ម ស្ថិតនៅក្នុងឃុំអូរដា និងឃុំតាក្រី ស្រុកកំរៀង ខេត្តបាត់ដំបង។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តកំពង់ឆ្នាំង ស្នើសុំកាត់ដីទំហំ ១៥ហិកតា ចេញពីដីជាប់ តំបន់វាលទំនាបដែលលិចទឹកក្នុងរដូវទឹកឡើងនៃដីដែលទទួលរបបទឹកទន្លេមេគង្គ ដើម្បីរៀបចំវិនិយោគសាងសង់ ផ្សារ ផែដឹកជញ្ជូន ផែត្រី/កសិផល និងផែទេសចរណ៍សម្រាប់ប្រជាពលរដ្ឋប្រកបអាជីវកម្ម ស្ថិតនៅឃុំឆ្នុកទ្រូ ស្រុក បរិបូរណ៍ ដែលមានទំហំ ០៦ហិកតា ជាដីរបស់រដ្ឋ។

**៦.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ**

**៦.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល**

-រៀបចំ បន្តដំណើរការកិច្ចប្រជុំពិគ្រោះយោបល់លើកទី៦ ជាមួយតំណាងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ នឹងការស្នើសុំធ្វើវិសោធនកម្មច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តលើកយោបល់អំពីការសុំចុះឈ្មោះ សុំបើកទីស្នាក់ការសាខា សុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មី នៃរចនាសម្ព័ន្ធ សុំប្តូរទីស្នាក់ការកណ្តាល សុំប្តូរឈ្មោះ សុំធ្វើវិសោធនកម្មលក្ខន្តិកៈ សុំលុបឈ្មោះ ការផ្អាកសកម្មភាព សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសំណើផ្សេងៗដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច។

-បន្តលើកយោបល់អំពីការសុំតម្កល់សំណុំឯកសារ អំពីការផ្លាស់ប្ដូរសមាសភាពរចនាសម្ព័ន្ធ និងការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់សហគមន៍ជនជាតិដើមភាគតិច

-បន្តគាំទ្រកិច្ចដំណើរការរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តធ្វើបច្ចុប្បន្នភាព និងបូកសរុបនូវរបាយការណ៍សកម្មភាព និងការផ្ដល់លេខគណនីរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តតាមដាន ប្រមូលព័ត៌មានពីគ្រប់បណ្ដាញព័ត៌មានសង្គមពាក់ព័ន្ធនឹងការធ្វើសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តតាមដាន ត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលក្ខន្តិកៈរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តចូលរួមកិច្ចប្រជុំជាមួយក្រុមការងារត្រួតពិនិត្យរួមគ្នានៃប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ICRP-JG) នៃក្រុមការងារហិរញ្ញវត្ថុ (FATF)

-បន្តចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រជាតិ ស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១៩-២០២៣។

**៦.៤.២-ការងារគណបក្សនយោបាយ**

-បន្តពិនិត្យ លើកយោបល់ អំពីការសុំបង្កើត ឬការសុំចុះបញ្ជី និងសំណើនានា របស់គណបក្សនយោបាយ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច

-បន្តពិនិត្យ លើកយោបល់ នូវរាល់សំណើពាក់ព័ន្ធនឹងការផ្លាស់ប្ដូរ ឬការប្រែប្រួលនានារបស់គណបក្សនយោបាយ

-បន្តតាមដានពិនិត្យបូកសរុបប្រមូលព័ត៌មាន ពីគ្រប់បណ្ដាញព័ត៌មានសង្គម និងរបាយការណ៍របស់រដ្ឋបាលរាជធានី ខេត្ត ចំពោះគណបក្សនយោបាយ ដែលបានធ្វើសកម្មភាពផ្ទុយពីលក្ខន្តិកៈ ច្បាប់ស្ដីពីគណបក្សនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននានា

-រៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះគណបក្សនយោបាយ ដែលបានបង្កើត បានចុះបញ្ជី និងត្រូវបានលុបឈ្មោះ

-បែងចែក ដើម្បីផ្សព្វផ្សាយសៀវភៅច្បាប់ស្ដីពីគណបក្សនយោបាយ ជូនថ្នាក់ដឹកនាំអង្គភាពចំណុះក្រសួងមហាផ្ទៃ ក្រសួង-ស្ថាប័ននានា និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**អគ្គនាយក**

ប្រាក់ សំអឿន

__ចម្លងជូន៖__

*-ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ*
*(ជូនជ្រាបជាសេចក្ដីរាយការណ៍)*
*-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ*
*-អគ្គស្នងការដ្ឋាននគរបាលជាតិ*
*-អគ្គនាយកដ្ឋានកស្តុការ និងហិរញ្ញវត្ថុ*
*-អគ្គាធិការដ្ឋាន*
*-អគ្គនាយកដ្ឋានពន្ធនាគារ*
*-គ្រប់នាយកដ្ឋានចំណុះអ.រ.ប*
*"ដើម្បីជូនជ្រាប"*
*-ឯកសារ-កាលប្បវត្តិ*